


ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ
ចក្ខុវិស័យឆ្នាំ២០៣០


អាសយដ្ឋានៈ ដីឡូត៏លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ/ទូរសារ (៨៥៥) ២៣ ២១៥ ៦៦០ / ២៣ ២១៥ ២៧៧
គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabitnet!gmail.com


ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ចក្ខុវិស័យឆ្នាំ២០៣០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ

## ចក្ខុវិស័យឆ្នាំ២០៣០

រៀបចំដោយ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់


បោះពុម្ពផ្សាយលើកទី១
ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣, ខែឧសភា ឆ្នាំ២០១៩

# ប្លង់គោលប្រើប្រាស់ដីធ្លីប្រជុំជនធំ

## ចក្ខុវិស័យឆ្នាំ២០៣០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

លេខ: ០០៥ សរសរ

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនថ្មែធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
### និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៤ ស្ដីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១២ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០១៥ ស្ដីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញសេចក្ដីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្ដីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

-យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្ដាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្ដីសម្រេចនេះ។

**ប្រការ ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្ដាល និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកកោះធំ ត្រូវរៀបចំផែនការ សម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកកោះធំ ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្ដង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំមុនពេលកំណត់អាចប្រព្រឹត្តទៅបាន ក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ត្រូវអនុវត្តតាមនីតិវិធី ដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្តាល និងអភិបាលនៃគណៈអភិបាលស្រុកកោះធំ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកកោះធំ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃចន្ទ ២ កោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ...០០៥ សសរ...ចុះថ្ងៃ...ចន្ទ ២ រោច ...ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ត្រូវនឹងថ្ងៃទី...២៤......ខែ...ធ្នូ......ឆ្នាំ ២០១៨

ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីធ្លីប្រជុំជនព្រែកធំ ស្រុកកោះធំ ខេត្តកណ្តាល

# ប្លង់គោលប្រើប្រាស់ដីធ្លីប្រជុំជនព្រែកធំ
# ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល
# ចក្ខុវិស័យឆ្នាំ ២០៣០

## មាតិកា

ទំព័រ


១- សេចក្តីផ្តើម........................................................................ ១

២- ចក្ខុវិស័យ ........................................................................ ២

២.១-ក្របខណ្ឌសេដ្ឋកិច្ច-សង្គម........................................................ ២

២.២-ចក្ខុវិស័យ ........................................................................ ៣

៣- គោលបំណង និងគោលដៅ.......................................................... ៣

៣.១-គោលបំណង ........................................................................ ៣

៣.២-គោលដៅ............................................................................ ៣

៤- យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីប្រជុំជនជ្រៃធំ ................................................ ៤

៤.១-យុទ្ធសាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព........................ ៤

៤.១.១-ការអភិវឌ្ឍទីប្រជុំជន និងនគរូបនីយកម្ម............................................ ៤

៤.១.២-យុទ្ធសាស្ត្រគ្រប់គ្រង និងការប្រើប្រាស់ដី............................................ ៥

៤.២-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍................................................ ១៤

៤.២.១-តំបន់ទេសចរណ៍វប្បធម៌ និងសោភ័ណភាពទីប្រជុំជន.................................... ១៤

៤.២.២-តំបន់ទេសចរណ៍ធម្មជាតិ............................................................ ១៤

៤.២.៣-ខ្សែទស្សនាកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍ ........................ ១៥

៤.២.៤-ការអភិវឌ្ឍធនធានមនុស្ស............................................................ ១៦

៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម.................................. ១៦

៤.៣.១-អ័ក្សអភិវឌ្ឍន៍ទេសចរណ៍ ពាណិជ្ជកម្ម រាជធានីភ្នំពេញ ខេត្តកណ្តាល ភ្ជាប់ទៅអន្តរជាតិ.................. ១៦

៤.៣.២-ផ្លូវថ្នល់........................................................................ ១៦

៤.៣.៣-ផ្លូវទឹក........................................................................ ១៧

៤.៣.៤-ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា.............................. ១៧

៤.៣.៥-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌.............................................. ១៧

៤.៣.៦ -ការផ្គត់ផ្គង់ទឹកស្អាត.............................................................. ១៨

៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក.................................. ១៩

៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច.................................................... ១៩

៤.៦- យុទ្ធសាស្ត្រការពារបរិស្ថាន និងធនធានធម្មជាតិ ............ ២០
៤.៦.១- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង ............ ២០
៤.៦.២- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ ............ ២០
៤.៦.៣- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន ............ ២១
៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ ............ ២១
៤.៧- យុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្ម ............ ២១
៤.៨- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ............ ២២
៤.៩- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ ............ ២៣
៤.១០- យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅតាមមូលដ្ឋាន ............ ២៣
៤.១១- យុទ្ធសាស្ត្រការពារព្រំដែន ............ ២៤
៥- ផែនការសកម្មភាព ............ ២៤
៥.១- ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម ............ ២៥
៥.២- ការផ្សព្វផ្សាយ ............ ២៥
៥.៣- ការអនុវត្តគម្រោងតាមវិស័យ ............ ២៥
៥.៣.១- ការអភិវឌ្ឍទីប្រជុំជន ............ ២៥
៥.៣.២- ការអភិវឌ្ឍវិស័យទេសចរណ៍ ............ ២៥
៥.៣.៣- ការដឹកជញ្ជូន ............ ២៦
៥.៣.៤- ការអភិវឌ្ឍតំបន់ពាណិជ្ជកម្ម ............ ២៦
៥.៣.៥- ការគ្រប់គ្រងបរិស្ថាន ............ ២៦
៥.៣.៦- ការគ្រប់គ្រងធនធានទឹក និងផ្គត់ផ្គង់ទឹកស្អាត ............ ២៧
៥.៣.៧- ការគ្រប់គ្រងប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ ............ ២៧
៥.៣.៨- ការគ្រប់គ្រងសំណល់រឹង ............ ២៧
៥.៣.៩- ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍ ............ ២៧
៥.៤- ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង ............ ២៨
៥.៤.១- ការអនុវត្តរយៈពេលខ្លី ............ ២៨
៥.៤.២- ការអនុវត្តរយៈពេលមធ្យម ............ ៣០
៥.៤.៣- ការអនុវត្តរយៈពេលវែង ............ ៣១

៦- ធនធានហិរញ្ញវត្ថុ ................................................ ៣២

៧- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ................................................ ៣២

៧.១- យន្តការ ................................................ ៣២

៧.២- ច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្ត ................................................ ៣២

៧.៣- ភារកិច្ច នីតិវិធី និងគោលការណ៍ ................................................ ៣២

៨- សេចក្តីសន្និដ្ឋាន ................................................ ៣៣

៩- អនុសាសន៍ ................................................ ៣៤

សទ្ទានុក្រម ................................................ ៣៥

ឯកសារឧបសម្ព័ន្ធ ................................................ ៣៨

## ១- សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ច និងកិច្ចការពារធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដី ដោយបានយកចិត្តទុកដាក់លើការរៀបចំផែនការរូបវន្ត សម្រាប់ការអភិវឌ្ឍនៅគ្រប់កម្រិតថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា។ តំបន់ជ្រៃធំ កំពុងក្លាយជាទីប្រជុំជនព្រំដែនដែលមានការអភិវឌ្ឍយ៉ាងសកម្ម និងជាច្រកទ្វារអន្តរជាតិជ្រៃធំ-ឡុងប៊ិន រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម តាមរយៈសមិទ្ធផលថ្មីៗរបស់រាជរដ្ឋាភិបាល ដូចជា ផ្លូវជាតិលេខ២១ ស្ពានមិត្តភាពកម្ពុជា-វៀតណាម និងផ្លូវទឹកទន្លេបាសាក់ តភ្ជាប់ពីរាជធានីភ្នំពេញឆ្ពោះទៅប្រទេសវៀតណាម សម្រាប់ដឹកទំនិញ ដឹកអ្នកដំណើរ និងភ្ញៀវទេសចរ ដែលកំពុងមានកំណើនខ្ពស់ទាំងនេះ គឺជាសក្តានុពលក្នុងតំបន់ដ៏សំខាន់មួយរបស់ខេត្តកណ្តាល។

ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ត្រូវបានកសាងឡើងដោយមានការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន ដោយផ្អែកលើគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្ម មានជាអាទិ៍ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ មានលក្ខណៈទូលំទូលាយគ្របដណ្ដប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេស សម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយចីរភាព ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការក្នុងការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់វិស័យក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានទឹក ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិ ជាពិសេសការអភិរក្សទន្លេបាសាក់ ព្រែក និងបឹង ដែលអាចទទួលផលប៉ះពាល់ដោយសារសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ឬដោយសារការប្រែប្រួលអាកាសធាតុ ដូចជា ការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្ដៅក្នុងទីប្រជុំជន របបទឹកភ្លៀងមិនទៀងទាត់ ទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះជាដើម។ ក្រៅពីនេះ ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំរួមជាមួយនឹងច្រកទ្វារអន្តរជាតិជ្រៃធំ នឹងក្លាយទៅជាយុទ្ធសាស្ត្រការពារព្រំប្រទល់ប្រទេស ឱ្យមានសន្តិសុខ ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការបង្កើនការងារ និងការកាត់បន្ថយភាពក្រីក្រ។

## ២- ចក្ខុវិស័យ

### ២.១-ក្របខណ្ឌសេដ្ឋកិច្ច-សង្គម

ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ត្រូវបានរៀបចំឡើងដោយបានសិក្សាប្រមូល និងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច សង្គម បរិស្ថាន ប្រជាសាស្ត្រ និងការស្រង់មតិ ស្របតាមគោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី (សៀវភៅ ស ដីធ្លី) និងអនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងសេចក្ដីសម្រេចស្ដីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ដើម្បីកំណត់ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ដល់ឆ្នាំ២០៣០ ក្របខណ្ឌសេដ្ឋកិច្ច សង្គម ត្រូវបានសិក្សាវិភាគតាមបែបវិទ្យាសាស្ត្រ ដោយផ្អែកតាមរបាយការណ៍ជាតិស្ដីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ដែលមានផ្ទៃក្រឡា២ ១៥៤,៨៣ ហិកតា ចំនួនប្រជាជននៅឆ្នាំ២០០៨ មានចំនួន ៥ ៦៩៧ នាក់ នៅឆ្នាំ២០១៨ មានចំនួន៧ ០៣៧ នាក់ ហើយនៅឆ្នាំ២០៣០ នឹងកើនដល់១៣ ១៣៤ នាក់។

ជាមួយគ្នានេះ ការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល នៅឆ្នាំ២០០៨ ចំនួនប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មមានចំនួន១ ៩០៩ នាក់ ស្មើនឹង៥៦,០៨% វិស័យឧស្សាហកម្ម៩៥ នាក់ ស្មើនឹង២,៧៩% និងវិស័យសេវាកម្ម១ ៤០០ នាក់ ស្មើនឹង ៤១,១៣% ហើយរំពឹងថានៅឆ្នាំ២០៣០ ចំនួនប្រជាជនដែលធ្វើការកសិកម្មមានចំនួនថយចុះមកត្រឹម៣៩៤ នាក់ ស្មើនឹង៥% វិស័យឧស្សាហកម្ម មានការកើនឡើងមានចំនួន១ ៧៣៤ នាក់ ស្មើនឹង២២% និងវិស័យសេវាកម្ម មានការកើនឡើងមានចំនួន៥ ៧៥៣ នាក់ ស្មើនឹង៧៣%។

## ២.២- ចក្ខុវិស័យ

ចក្ខុវិស័យ ឆ្នាំ២០៣០ នៃប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ គឺសំដៅរៀបចំ និងអភិវឌ្ឍ **"ជាទីប្រជុំជនព្រំដែនមិត្តភាព សន្តិភាព សហប្រតិបត្តិការ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសេវាកម្ម ប្រកបដោយចីរភាព"** តាមរយៈការរៀបចំ និងបង្កើតទៅជា÷ ១). តំបន់ពាណិជ្ជកម្ម សេវាកម្ម និងដឹកជញ្ជូន ប្រកបដោយភាពលេចធ្លោ និងប្រសិទ្ធភាពខ្ពស់ ២). តំបន់ទេសចរណ៍ និងលម្ហែកម្សាន្តប្រកបដោយភាពទាក់ទាញ និងការពេញនិយម ៣). តំបន់ដែលមានសន្តិភាព និងសហប្រតិបត្តិការអន្តរជាតិ ប្រកបដោយភាតរភាព ៤). តំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធ និងអភិបាលកិច្ចល្អ ដើម្បីឆ្លើយតបបានតាមតម្រូវការរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍដីធ្លីប្រកបដោយចីរភាពនៅតាមព្រំដែន ៥). តំបន់ទីប្រជុំជនប្រកបដោយសុខដុមនីយកម្មនៃការរស់នៅ និងប្រកបការងារ សំដៅរៀបចំឱ្យក្លាយទៅជាទីប្រជុំជនទំនើបនាពេលអនាគត។

វិសាលភាពនៃការសិក្សាប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ សម្រាប់ចក្ខុវិស័យឆ្នាំ២០៣០ មានការសិក្សាលម្អិតចំនួន ៣ ភូមិ គឺភូមិព្រែកស៊ីង ភូមិជ្រៃធំ និងភូមិព្រែកស្បូវ ដែលមានផ្ទៃដីសរុប២ ១៥៤,៨៣ ហិកតា ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល។

# ៣- គោលបំណង និងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន មានគោលបំណង និងគោលដៅ ដូចខាងក្រោម÷

## ៣.១- គោលបំណង

ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ មានគោលបំណងធានាការគ្រប់គ្រងដី ការប្រើប្រាស់ដី ការអភិវឌ្ឍ និងការអភិរក្ស ប្រកបដោយប្រសិទ្ធភាព គុណភាព តុល្យភាព ចីរភាព និងសមធម៌។

## ៣.២- គោលដៅ

ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ មានគោលដៅ÷

- គ្រប់គ្រង ការពារ រៀបចំ ប្រើប្រាស់ អភិវឌ្ឍដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ចីរភាព សមធម៌ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម បរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី
- ជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍន៍ធុរកិច្ចទាក់ទាញ ដើម្បីគាំទ្រដល់ការវិនិយោគសាធារណៈ និងឯកជន
- គ្រប់គ្រងដីរដ្ឋ ធនធានធម្មជាតិ បរិស្ថាន ជំរុញអភិវឌ្ឍន៍បៃតង និងបង្ការទប់ស្កាត់គ្រោះមហន្តរាយ
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃការកែលម្អ ការអភិវឌ្ឍ និងការពារហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យ ដើម្បីធានាភាពសុខដុមនីយកម្មសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព

- ដោះស្រាយ និងឆ្លើយតបបានល្អ តាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទូទៅ និងតម្រូវការគ្រប់គ្រងជាក់ស្តែងរបស់អាជ្ញាធរមានសមត្ថកិច្ច
- រៀបចំយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចរវាងទីប្រជុំជនជ្រៃធំ ជាមួយតំបន់នៅជុំវិញ និងកិច្ចសហការនៅកម្រិតថ្នាក់ជាតិ និងអន្តរជាតិ។

## ៤- យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីប្រជុំជនជ្រៃធំ

ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ជាមជ្ឈមណ្ឌលសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានទីតាំងស្ថិតនៅប៉ែកខាងត្បូងនៃប្រទេសកម្ពុជា ចម្ងាយប្រមាណ៦៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ២១ និងមានព្រំប្រទល់ជាប់ខេត្តអានយ៉ាងនៃប្រទេសវៀតណាម មានផ្ទៃដីសរុបប្រមាណ៦ ៧០១,២៨ ហិកតា មានភូមិចំនួន ១១ គឺភូមិជ្រៃធំ ភូមិព្រែកស៊ីង ភូមិព្រែកស្បូវ ភូមិព្រែកគង់ ភូមិក្បាលកោះទៀវ ភូមិកោះទៀវ (ក) ភូមិកោះទៀវ (ខ) ភូមិព្រែកសែម ភូមិខ្ពប ភូមិកំពង់ថ្កុល និងភូមិកប៉ាល់គៀង មានប្រជាជនសរុបចំនួន ២២ ៦៦៣ នាក់ នៅឆ្នាំ ២០១៥ មានដង់ស៊ីតេប្រជាជនស្មើនឹង ៣៣៧ នាក់/គ.ម²។

តំបន់ទីប្រជុំជនជ្រៃធំមាន ៣ ភូមិ គឺ ភូមិជ្រៃធំ ភូមិព្រែកស៊ីង និងភូមិព្រែកស្បូវ ស្ថិតនៅក្នុងឃុំសំពៅពូន មានផ្ទៃដីសរុបប្រមាណ ២ ១៥៤,៨៣ ហិកតា មានប្រជាជនសរុបចំនួន៥ ៣៦៦ នាក់ នៅឆ្នាំ២០១៥ និងមានដង់ស៊ីតេប្រជាជនស្មើនឹង២៤៩ នាក់/គ.ម²។ ជាតំបន់វាលទំនាបនៅតាមព្រំដែន ដែលសម្បូរទៅដោយផ្លូវទឹក និងដីធ្លីប្រកបដោយសក្តានុពលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម និងកសិកម្ម។

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ត្រូវបានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ច ការធ្វើសមាហរណកម្ម ការអភិវឌ្ឍ និងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌ ដូចខាងក្រោម÷

### ៤.១- យុទ្ធសាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព

#### ៤.១.១- ការអភិវឌ្ឍទីប្រជុំជន និងនគរូបនីយកម្ម

##### ក)- តំបន់ទីប្រជុំជនបច្ចុប្បន្ន

- ជំរុញការដាក់លេខផ្ទះ ឈ្មោះផ្លូវ និងលេខផ្លូវ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង
- កែលម្អ ស្ពា ប្រឡាយ ព្រែក និងរៀបចំសួន និងដាំដើមឈើតាមដងទន្លេបាសាក់ ដងព្រែកជ្រៃធំ ផ្លូវ និងភ្លើងបំភ្លឺ ឱ្យមានសោភ័ណភាព គុណភាពបរិស្ថានល្អ និងសកម្មភាពរស់រវើកទាំងពេលយប់ និងពេលថ្ងៃ
- កែលម្អ និងរៀបចំវិថី អនុវិថី ផ្លូវថ្មើរជើង បណ្តាញផ្លូវ លម្ហសាធារណៈ កំណត់ប្រភេទ និងដាំដើមឈើ រៀបចំសួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍន៍ផ្ទៃបៃតងនៅក្នុងទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ស្របទៅតាមតំបន់ប្រើប្រាស់ដី ឱ្យមានសោភ័ណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ និងបរិស្ថានរស់នៅប្រកបដោយផាសុកភាព

- កំណត់តំបន់ដែលត្រូវរៀបចំកែលម្អទីប្រជុំជនថ្មីនិងចាស់ កែលម្អ និងស្តារបណ្តាញហេដ្ឋារចនាសម្ព័ន្ធ មានបណ្តាញផ្លូវ ប្រព័ន្ធទឹកស្អាត បណ្តាញអគ្គិសនី ការប្រមូលសំណល់រឹង និងរាវ ឱ្យមានលក្ខណៈសមស្រប និងមានគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅ និងសោភ័ណភាពទីប្រជុំជន
- រៀបចំ និងកំណត់រចនាបថអគារ ពណ៌អគារ និងកំណត់ផ្លាកសញ្ញាផ្សាយពាណិជ្ជកម្ម តាមដងផ្លូវ និងតាមតំបន់ឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាពល្អ ស្របតាមទីតាំងភូមិសាស្ត្រ
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍដី ការសាងសង់ និងប្លង់លម្អិតនគរូបនីយកម្ម តាមតំបន់នីមួយៗ នៃគម្រោង។

**ខ)-ទិសដៅនគរូបនីយកម្ម**

- ការអភិវឌ្ឍទីប្រជុំជន និងនគរូបនីយកម្មមាននិន្នាការ និងពង្រីកឆ្ពោះទៅទិសខាងជើង ទិសខាងលិច និងទិសឦសាននៃទីប្រជុំជនជ្រៃធំបច្ចុប្បន្ន ដោយខិតខំការពារផ្ទៃដីសក្តានុពលកសិកម្មខ្ពស់ ការពារប្រភពទឹក និងអាងស្តុកទឹកធម្មជាតិ មានជាអាទិ៍ ទន្លេ ព្រែក ប្រឡាយ បឹង
- រៀបចំផែនការកំណត់កម្ពស់អគារ ទាប មធ្យម និងខ្ពស់ ក្នុងទីប្រជុំជនបច្ចុប្បន្ន
- គ្រប់គ្រងការអភិវឌ្ឍ និងធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយប្រសិទ្ធភាព និងចីរភាព ស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្ម និងការអភិវឌ្ឍរូបវន្ត ជាពិសេសបណ្តាញផ្លូវ ប្រព័ន្ធលូ ប្រព័ន្ធគ្រប់គ្រងកាកសំណល់ និងជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាមុន
- ពង្រឹងសមត្ថភាពមន្ត្រី ក្នុងការកសាងផែនការរូបវន្ត និងគ្រប់គ្រងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាព ជាពិសេសមន្ត្រីគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត និងក្រុង ស្រុក មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ដែលជាសេនាធិការលើការងាររៀបចំដែនដី និងនគរូប-នីយកម្ម។

### ៤.១.២-យុទ្ធសាស្ត្រគ្រប់គ្រង និងការប្រើប្រាស់ដី

ទីប្រជុំជនជ្រៃធំមានផ្ទៃដីប្រមាណ២ ១៥៤,៨៣ ហិកតា ត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺ ប្រភេទដីកម្រិតការសាងសង់ និងប្រភេទដីអាចសាងសង់បាន។ បច្ចុប្បន្នការប្រើប្រាស់ដី និងការសាងសង់នៅទីប្រជុំជនជ្រៃធំ ត្រូវបានអនុវត្តតាមស្ថានភាព និងតម្រូវការជាក់ស្តែងមិនទាន់បានឆ្លើយតបទៅនឹងសក្តានុពលទីតាំងភូមិសាស្ត្រ ប្រសិទ្ធភាព សេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។

ជាមួយគ្នានេះ តាមរយៈការសិក្សាប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ចក្ខុវិស័យ ឆ្នាំ២០៣០ ឃើញថា ប្រភេទដីកម្រិតការសាងសង់នឹងមានផ្ទៃដីប្រមាណ៣៦៤,០៧ ហិកតា ស្មើនឹង១៦,៩០% ប្រភេទដីអាចសាងសង់

បានមានផ្ទៃដីប្រមាណ១ ៧៩០,៧៦ ហិកតា ស្មើនឹង៨៣,១០%។ ក្នុងនោះដែរសម្រាប់ឃុំសំពៅពូនទាំងមូលមានផ្ទៃដីសរុបប្រមាណ៦ ៧០១,២៨ ហិកតា ប្រភេទដីកម្រិតការសាងសង់នឹងមានផ្ទៃដីប្រមាណ៣ ៤៧៥,០៤ ហិកតា ស្មើនឹង៥១,៨៦% ប្រភេទដីអាចសាងសង់មានផ្ទៃដីប្រមាណ ៣ ២២៦,២៤ ហិកតា ស្មើនឹង ៤៨,១៤%។

**ក)- ប្រភេទដីកម្រិតការសាងសង់**

ផ្អែកតាមអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវ និងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសលេខ៩៦១ សហវ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០០ ស្តីពីការចុះអនុវត្តគោលការណ៍ដីចំណីផ្លូវជាតិ ផ្លូវខេត្ត ផ្លូវទូទាំងព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ ប្រភេទដីកម្រិតការសាងសង់នៃទីប្រជុំជនជ្រៃធំ ត្រូវបានបែងចែកជាតំបន់ ដែលបានកំណត់ក្នុងផែនទីប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំដែលជាឧបសម្ព័ន្ធ ដូចខាងក្រោម៖

**១-តំបន់កសិកម្ម÷** មានផ្ទៃដីប្រមាណ១១៦,៩៨ ហិកតា ស្មើនឹង៣១,៩៧% ជាប្រភេទដីស្រែ ស្ថិតនៅភូមិព្រែកស្បូវ និងភូមិជ្រៃធំ។

**២-តំបន់ធនធានទឹក÷** មានផ្ទៃដីប្រមាណ២២៣,៩៨ ហិកតា ស្មើនឹង៦១,៥២% ដែលគ្របដណ្តប់ផ្នែកខ្លះនៃភូមិទាំងបី ដែលតំបន់ផ្ទៃទឹកទាំងនោះ ដូចជា÷

- ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់នេះត្រូវកំណត់÷
  - ទន្លេបាសាក់ មានផ្ទៃដីប្រមាណ៤២,៩៨ ហិកតា
  - ព្រែក៧៥ (ព្រែកស៊ឹង) មានផ្ទៃដីប្រមាណ៧ ហិកតា ស្ថិតនៅភូមិព្រែកស៊ឹង
  - ព្រែក៧៦ មានផ្ទៃដីប្រមាណ៤ ហិកតា ស្ថិតនៅភូមិព្រែកស៊ឹង
  - ព្រែក៧៧ មានផ្ទៃដីប្រមាណ១០ ហិកតា ស្ថិតនៅភូមិព្រែកស៊ឹង
  - ព្រែកជ្រៃធំ មានផ្ទៃដីប្រមាណ៥២ ហិកតា ស្ថិតនៅភូមិព្រែកស្បូវ
  - ផ្ទៃទឹកសំពៅជ្រៃ មានផ្ទៃដីប្រមាណ ៩៨ ហិកតា ស្ថិតនៅជាប់ភូមិទាំងបីនៃតំបន់ជ្រៃធំ ដែលមាននិយាមកាចំណុចកណ្តាល (X=504763,Y=1209949)
  - ប្រឡាយតភ្ជាប់ពីផ្ទៃទឹកសំពៅជ្រៃមកដៃព្រែកជ្រៃធំមានផ្ទៃដីប្រមាណ១០ ហិកតា ស្ថិតនៅភូមិព្រែកស្បូវ។

**៣-តំបន់ការពារ÷** មានផ្ទៃដីប្រមាណ៧,៣០ ហិកតា ស្មើនឹង២,០១% ស្ថិតនៅភូមិជ្រៃធំ ដែលមាននិយាមកាចំណុចកណ្តាល(X=508549,Y=1209460)÷

- តំបន់ការពារស្ថិតនៅច្រាំងទន្លេបាសាក់ពីផ្លូវជាតិលេខ២១ រហូតដល់ព្រំដែននៃប្រទេសកម្ពុជា-វៀតណាម១០០ ម៉ែត្រ
- តំបន់ការពារមួយផ្នែកទៀតមាននៅតាមតំបន់បង្គោលព្រំដែន ស្ថិតនៅតាមព្រែកជ្រៃធំ និងខាងកើតនៃដងទន្លេបាសាក់។

៤-តំបន់ផ្សេងៗ÷

- តំបន់ទុកដាក់សំរាមបណ្តោះអាសន្នមានផ្ទៃដីប្រមាណ១ ហិកតា ស្ថិតនៅភូមិព្រៃកស៊ឹង ដែលមាននិយាមកាចំណុចកណ្តាល (X=505548,Y=1210510)
- ទីតាំងទុកដាក់ និងប្រមូលសំរាមបណ្តោះអាសន្នមានចំនួន ៧ ទីតាំងដូចជា÷
    - ទីតាំងទី១. ស្ថិតនៅភូមិព្រៃកស៊ឹង មានចម្ងាយ២៦ ម៉ែត្រ ពីផ្លូវជាតិលេខ២១ និងមាននិយាមកាចំណុចកណ្តាល (X=506824,Y=1212176)
    - ទីតាំងទី២. ស្ថិតនៅភូមិព្រៃកស៊ឹង មានចម្ងាយ ១ ០០៨ ម៉ែត្រ ផ្លូវជាតិលេខ២១ និងមាននិយាមកាចំណុចកណ្តាល (X=506326,Y=1211548)
    - ទីតាំងទី៣. ស្ថិតនៅភូមិជ្រៃធំ ជាប់ផ្លូវជាតិលេខ២១ថ្មី មានចម្ងាយ ៣៨៨ ម៉ែត្រ និងមាននិយាមកាចំណុចកណ្តាល (X=507673,Y=1211618)
    - ទីតាំងទី៤. ស្ថិតនៅភូមិជ្រៃធំ ស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស មានចម្ងាយ៥៦៩ ម៉ែត្រ និងមាននិយាមកាចំណុចកណ្តាល (X=508152,Y=1210640)
    - ទីតាំងទី៥. ស្ថិតនៅភូមិជ្រៃធំ មានចម្ងាយ១ ០៥១ ម៉ែត្រ ពីកំណាត់ផ្លូវជាតិលេខ២១ថ្មី និងមាននិយាមកាចំណុចកណ្តាល (X=508390,Y=1211155)
    - ទីតាំងទី៦. ស្ថិតនៅភូមិជ្រៃធំ ក្នុងតំបន់ពាណិជ្ជកម្ម និងមាននិយាមកាចំណុចកណ្តាល (X=506461,Y=1210253)
    - ទីតាំងទី៧. ស្ថិតនៅភូមិព្រៃកស្បៅ ស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស និងមាននិយាមកាចំណុចកណ្តាល (X=504917,Y=1207077)។
- ស្ថានីយបូមទឹកមានចំនួន ៦ ទីតាំងដូចជា÷
    - ទីតាំងទី១. ស្ថិតនៅភូមិព្រៃកស៊ឹង មានចម្ងាយ៣០ ម៉ែត្រ ពីផ្លូវជាតិលេខ២១ និងមាននិយាមកាចំណុចកណ្តាល (X=506640,Y=1212399)
    - ទីតាំងទី២. ស្ថិតនៅភូមិជ្រៃធំ មានចម្ងាយ៩០០ ម៉ែត្រ ពីកំណាត់ផ្លូវលេខ២១ថ្មី និងមាននិយាមកាចំណុចកណ្តាល (X=508166,X=1211370)
    - ទីតាំងទី៣. ស្ថិតនៅភូមិព្រៃកស្បៅ ក្នុងតំបន់លំនៅឋាន និងមាននិយាមកាចំណុចកណ្តាល (X=503673,Y=1205550)
    - ទីតាំងទី៤. ស្ថិតនៅភូមិព្រៃកស្បៅ ក្នុងតំបន់កសិកម្ម និងមាននិយាមកាចំណុចកណ្តាល (X=504810, Y=1209085)
    - ទីតាំងទី៥. ស្ថិតនៅភូមិព្រៃកស្បៅ ក្នុងតំបន់លំនៅឋាន និងមាននិយាមកាចំណុចកណ្តាល (X=503673,Y=1205550)
    - ទីតាំងទី៦. ស្ថិតនៅភូមិជ្រៃធំ ក្នុងតំបន់លំនៅឋាន និងមាននិយាមកាចំណុចកណ្តាល (X=505299, Y=1210260)។

- ស្ថានីយប្រេងឥន្ធនៈមានផ្ទៃដីប្រមាណ0,៨៩ ហិកតា មានចំនួន២ ទីតាំងដូចជា÷
  - ទីតាំងទី១. ស្ថិតនៅភូមិព្រៃកស៊ីង ក្នុងតំបន់ចម្រុះ និងមាននិយាមកាចំណុចកណ្តាល (X=505561,Y=1211266)
  - ទីតាំងទី២. ស្ថិតនៅភូមិព្រៃកស្បូវ ក្នុងសេដ្ឋកិច្ចពិសេស និងមាននិយាមកាចំណុចកណ្តាល (X=505214,Y=1208073)។
- អាងប្រព្រឹត្តិកម្មទឹកមានផ្ទៃដីប្រមាណ១៤,៥0 ហិកតា ដែលមាននិយាមកាចំណុចកណ្តាល (X=505561,Y=1211266) មានចំនួន១ ទីតាំងដូចជា÷
  - ទីតាំងទី១. ស្ថិតនៅភូមិជ្រៃធំ ក្នុងតំបន់ពាណិជ្ជកម្ម និងមាននិយាមកាចំណុចកណ្តាល (X=506402,Y=1210030)
  - ទីតាំងទី២. ស្ថិតនៅភូមិជ្រៃធំ និងមាននិយាមកាចំណុចកណ្តាល (X=505172, Y=1207230)។

គម្រោងអភិវឌ្ឍន៍ និងសាងសង់ក្នុងប្រភេទដីកម្រិតការសាងសង់នេះ តម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុន ស្របតាមអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី0៣ ខែមេសា ឆ្នាំ២0១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងប្រកាសលេខ0៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២0១៨ ស្តីពីការអភិវឌ្ឍដី។

មានតែតំបន់កសិកម្មប៉ុណ្ណោះដែលអាចអនុញ្ញាតឱ្យសាងសង់លំនៅឋានផ្ទាល់ខ្លួនបានដែលមិនមានលក្ខណៈអាជីវកម្ម និងអាចសាងសង់រោងសិប្បកម្មសម្រាប់គោលដៅកសិកម្មបាន ដោយមិនចាំបាច់ធ្វើការកែប្រែទៅជាប្រភេទដីអាចសាងសង់បាន លើកលែងតែតំបន់ណាមានបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់កសិកម្ម ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង 0,៥ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូតិ៍អតិបរមាស្មើនឹង១0% ផ្លាតម្លាតអគារខាងមុខយ៉ាងតិច ១0 ម៉ែត្រ និងចំហៀងសងខាងនិងខាងក្រោយយ៉ាងតិចស្មើនឹងពាក់កណ្តាលគម្លាតអគារខាងមុខកម្ពស់អគារអតិបរមាស្មើនឹង៨ ម៉ែត្រ សួនច្បារអាចជ្រាបទឹកនិងផ្ទៃបៃតងយ៉ាងតិច៦៥%នៃផ្ទៃដីដែលនៅសល់ពីការសាងសង់ និងដាំដើមឈើយ៉ាងតិច១ ដើមសម្រាប់ផ្ទៃក្រឡាដីឡូតិ៍៤៩ ម៉ែត្រក្រឡា។

### ខ)-ប្រភេទដីអាចសាងសង់បាន

ផ្អែកលើផែនទីប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ចក្ខុវិស័យឆ្នាំ២0៣0 ប្រភេទដីអាចសាងសង់បានត្រូវបានកំណត់ជាតំបន់។ បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់នីមួយៗត្រូវមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូតិ៍ សួនច្បារដែលអាចជ្រាបទឹក ការដាំដើមឈើ ផ្លូវតម្រង់ ផ្លាតម្លាត កម្ពស់ ចំណតរថយន្ត អាងបង្គន់អនាម័យ ពណ៌អគារ សោភ័ណភាព និងមានរចនាបថស្ថាបត្យកម្មខ្មែរ និង/ឬមានធម្មជាតិត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិជាធរមាន និងបែងចែកតំបន់នៃផែនការប្រើប្រាស់ដីដូចខាងក្រោម÷

**១-តំបន់លំនៅឋាន÷** មានផ្ទៃដីប្រមាណ៣៤៣,០២ ហិកតា ស្មើនឹង១៩,១៥% ស្ថិតនៅភូមិទាំងបីនៃទីប្រជុំជនជ្រៃធំ និងមួយផ្នែកទៀតនៅស្របតាមច្រាំងទន្លេបាសាក់ទៅជាប់នឹងប្រទេសវៀតណាម។ តំបន់លំនៅឋានត្រូវបានកំណត់បែងចែកជា÷

- តំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥
- តំបន់លំនៅឋានជាប់គ្នាដែលមានកម្ពស់ទាបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥
- តំបន់លំនៅឋានដែលមានកម្ពស់មធ្យមត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០
- តំបន់លំនៅឋានចម្រុះ ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០
- ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់នេះត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង៥០%
  - ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីសរុប
  - ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខ១០ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង៥ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិដោយឡែក
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ
  - ត្រូវមានចំណតរថយន្តតូច១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់១០០ ម៉ែត្រក្រឡា។

**២-តំបន់ពាណិជ្ជកម្ម÷** មានផ្ទៃដីប្រមាណ៣៣១,៩២ ហិកតា ស្មើនឹង១៨,៥៤% បច្ចុប្បន្នស្ថិតនៅភូមិទាំងបីស្របតាមរង្វង់មូលផ្លូវជាតិលេខ២១ នៃភូមិព្រែកស៊ីង ដល់រង្វង់មូលនៃភូមិព្រែកស្បូវ។

- ផ្សារ មានផ្ទៃដីប្រមាណ៥,៥ ហិកតា ស្ថិតនៅភូមិព្រែកស៊ីង និងមាននិយាមកាចំណុចកណ្តាល (X=506728,Y=1211170)
- តំបន់ពាណិជ្ជកម្មត្រូវបានកំណត់បែងចែកជា÷
  - តំបន់ពាណិជ្ជកម្មត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៦,០
  - តំបន់ពាណិជ្ជកម្មចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០។
- ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់នេះត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ

- ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង៦០%
- ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច ៣០% នៃផ្ទៃដីសរុប
- ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខ៦ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង៣ ម៉ែត្រ
- ផ្ទៃក្រឡាដីឡូត៍១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ (មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិដោយឡែក
- ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ
- ត្រូវមានចំណតរថយន្តតូច១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់៥០ ម៉ែត្រក្រឡា។

**៣-តំបន់ចម្រុះ**÷មានផ្ទៃដីប្រមាណ២៥៧,៨៩ ហិកតា ស្មើនឹង១៤,៤៧% ស្ថិតនៅភូមិព្រែកស៊ីង ភាគខាងជើងជាប់នឹងភូមិកប៉ាល់គៀង។ តំបន់ចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៥,០។

- ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់នេះត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង៦០%
  - ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច ៣០% នៃផ្ទៃដីសរុប
  - ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខ ៥ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង២,៥ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ (មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិដោយឡែក
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ
  - ត្រូវមានចំណតរថយន្តតូច១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់១០០ ម៉ែត្រក្រឡា។

**៤-តំបន់ដឹកជញ្ជូន**÷ មានផ្ទៃដីប្រមាណ២០,៣១ ហិកតា ស្មើនឹង១,១៣% ស្ថិតនៅភូមិទាំងបីនៃតំបន់ទីប្រជុំជនជ្រៃធំ។

- ចំណតមានផ្ទៃដីប្រមាណ១៥,៥១ ហិកតា ដែលមានចំនួនបួនទីតាំងដូចជា÷
  - ទីតាំងទី១. ស្ថិតនៅភូមិជ្រៃធំ មានផ្ទៃដីប្រមាណ៣,៨៤ ហិកតា និយាមកាចំណុចកណ្ដាល (X=508343,Y=1210130)
  - ទីតាំងទី២. ស្ថិតនៅភូមិព្រែកស៊ីង មានផ្ទៃដីប្រមាណ៤,៥៨ ហិកតា និយាមកាចំណុចកណ្ដាល (X=506603,Y=1210960)
  - ទីតាំងទី៣. ស្ថិតនៅភូមិជ្រៃធំ មានផ្ទៃដីប្រមាណ២,៨៧ ហិកតា និយាមកាចំណុចកណ្ដាល (X=506714,Y=121211710)
  - ទីតាំងទី៤. ស្ថិតនៅភូមិជ្រៃធំ មានផ្ទៃដីប្រមាណ២,០៤ ហិកតា ក្នុងនោះដែលមានទីតាំងចំណតមាននិយាមកាចំណុចកណ្ដាល (X=507624,Y=1210820)។

- ផែស្លូតមានផ្ទៃដីប្រមាណ៦,៩៨ ហិកតា ស្ថិតនៅភូមិព្រែកស៊ីង មាននិយាមកាចំណុចកណ្តាល (X=506460,Y=1211650)
- ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់នេះត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង២
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង៥០%
  - ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីសរុប
  - ថ្លាតម្លាតអប្បបរមាផ្នែកខាងមុខ៥ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង២,៥ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ (មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិដោយឡែក
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ
  - ត្រូវមានចំណតរថយន្តតូច១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់១០០ ម៉ែត្រក្រឡា។

**៥-តំបន់ទេសចរណ៍÷** មានផ្ទៃដីប្រមាណ៦៥,៧៦ ហិកតា ស្មើនឹង៣,៦៧%។

- ទីតាំងទី១. មានផ្ទៃដីប្រមាណ៣២ ហិកតា ស្ថិតនៅភាគឦសាននៃតំបន់ទីប្រជុំជនជ្រៃធំ ស្របតាមទន្លេបាសាក់ និងនៅជុំវិញតំបន់ទឹកស្របផ្លូវមេ៥០ ម៉ែត្រ
- ទីតាំងទី២.រមណីយដ្ឋានសំពៅជ្រៃ ស្ថិតនៅភូមិជ្រៃធំ មានផ្ទៃដីប្រមាណ១៣២ ហិកតា ដែលមាននិយាមកាចំណុចកណ្តាល (X=504763, Y=1209949)
- ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់នេះត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង៥០%
  - ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីសរុប
  - ថ្លាតម្លាតអប្បបរមាផ្នែកខាងមុខ៥ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង២,៥ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ (មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិដោយឡែក
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ
  - ត្រូវមានចំណតរថយន្តតូច១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់១០០ ម៉ែត្រក្រឡា។

**៦-តំបន់ឧស្សាហកម្ម÷** តំបន់សេដ្ឋកិច្ចពិសេស ស្ថិតនៅភូមិព្រែកស្បូវ មានផ្ទៃដីប្រមាណ៦៦២,១៧ ហិកតា ស្មើនឹង៣៤,៧៤%។

- ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់នេះត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង២
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង៥០%
  - ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីសរុប
  - ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខ៥ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង២,៥ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍១២០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ (មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិដោយឡែក
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ
  - ត្រូវមានចំណតរថយន្តតូច១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់១០០ ម៉ែត្រក្រឡា។

**៧-តំបន់រដ្ឋបាលនិងសេវាសាធារណៈ÷**មានផ្ទៃដីប្រមាណ១២៤,៩៧ ហិកតា ស្មើនឹង៦,៩៨% មានដូចជា សាលារៀន សាកលវិទ្យាល័យ មន្ទីរពេទ្យ បណ្ណាល័យ រដ្ឋបាល ពហុកីឡដ្ឋាន ប៉ុស្តិ៍ប្រៃសណីយ៍។ តំបន់រដ្ឋបាលនិងសេវាសាធារណៈត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០។

- តំបន់ច្រកទ្វារត្រួតពិនិត្យអន្តរជាតិផ្លូវគោក មានផ្ទៃដីប្រមាណ៣,៨៧ ហិកតា ស្ថិតនៅភូមិជ្រៃធំ មាននិយាមកាចំណុចកណ្តាល (X=508045,Y=1210080)
- តំបន់ច្រកទ្វារត្រួតពិនិត្យអន្តរជាតិផ្លូវទឹក មានផ្ទៃដីប្រមាណ៣,៨៦ ហិកតា ស្ថិតនៅភូមិជ្រៃធំ មាននិយាមកាចំណុចកណ្តាល (X=508501,Y=1211210)
- ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់នេះត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង៥០%
  - ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីសរុប
  - ធ្លាគម្លាតអប្បបរមាផ្នែកខាងមុខ៨ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង៤ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ (មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិដោយឡែក
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ
  - ត្រូវមានចំណតរថយន្តតូច១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់១០០ ម៉ែត្រក្រឡា។

**៨-តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង÷** មានផ្ទៃដីប្រមាណ១៦,៨៩ហិកតា ស្មើនឹង០,៩៤% ស្ថិតនៅតាមបណ្ដោយទន្លេបាសាក់ និងនៅក្នុងភូមិជ្រៃធំស្របតាមផ្លូវមេ ដែលមានទទឹង៥០ ម៉ែត្រ។ តំបន់លម្ហសាធារណៈនិងផ្ទៃបៃតងត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង០,១។

- ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់នេះត្រូវកំណត់÷
  - សំណង់សាធារណៈត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - សួនច្បារសាធារណៈ និងដាំដើមឈើកំណត់បង្ហាញអំពីអត្តសញ្ញាណទីតាំងភូមិសាស្ត្រ
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ
  - ត្រូវរៀបចំចំណតរថយន្តសម្រាប់សាធារណៈ
  - ត្រូវរៀបចំសម្រាប់មនុស្សទូទៅរួមទាំងជនពិការ និងជនងាយរងគ្រោះ។

**៩-តំបន់វប្បធម៌និងសាសនា÷** មានផ្ទៃដីប្រមាណ៧,៧៣ ហិកតា ស្មើនឹង០,៤៣% ស្ថិតនៅភូមិព្រែកស្បូវមានវត្ត វិហារកាតូលិក។ តំបន់វប្បធម៌និងសាសនាត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង២,០។

- ការអភិវឌ្ឍ និងសាងសង់ក្នុងតំបន់នេះត្រូវកំណត់÷
  - សំណង់ត្រូវមានលក្ខណៈស្ថាបត្យកម្ម និងអត្តសញ្ញាណខ្មែរ
  - ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង៥០%
  - ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ត្រូវរៀបចំឱ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច ២៥% នៃផ្ទៃដីសរុប
  - ឆ្លាតម្លាតអប្បបរមាផ្នែកខាងមុខ៨ ម៉ែត្រ និងខាងក្រោយនិងចំហៀងសងខាង៤ ម៉ែត្រ
  - ផ្ទៃក្រឡាដីឡូត៍១០០ ម៉ែត្រក្រឡា ត្រូវដាំដើមឈើឱ្យបានយ៉ាងតិច១ (មួយ) ដើម លើកលែងតែមានបទប្បញ្ញត្តិដោយឡែក
  - ពណ៌អគារត្រូវមានលក្ខណៈវប្បធម៌ និងអត្តសញ្ញាណខ្មែរ
  - ត្រូវមានចំណតរថយន្តតូច១ កន្លែង សម្រាប់ក្រឡាផ្ទៃសំណង់១០០ ម៉ែត្រក្រឡា
  - ត្រូវរៀបចំសម្រាប់មនុស្សទូទៅរួមទាំងជនពិការ និងជនងាយរងគ្រោះ។

គម្រោងអភិវឌ្ឍន៍ និងសាងសង់ក្នុងប្រភេទដីអាចសាងសង់បាន តម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន និងត្រូវអនុវត្តតាមប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ដោយផ្អែកតាមអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ប្រកាសលេខ២១៧ ប្រក.ដ.ន.ស. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី និងប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/ទីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី។

## ៤.២- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ទីប្រជុំជនជ្រៃធំ មានសារៈសំខាន់ណាស់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍទេសចរណ៍នៅតាមតំបន់នីមួយៗ ក៏ដូចជាតំបន់ផ្សេងទៀតនៅទូទាំងប្រទេសកម្ពុជា។ ទីប្រជុំជនជ្រៃធំមានសក្តានុពលទេសចរណ៍ជាច្រើន ដែលអាចរៀបចំកែច្នៃ និងពង្រីកបាន ដូចជា តំបន់ទេសចរណ៍ធម្មជាតិតាមដងទន្លេបាសាក់ តាមដងព្រែកជ្រៃធំតាមបណ្តោយព្រែកស៊ឹងនៃស្ពាន៧៥ និងព្រែកស្ពាន៧៦ ព្រែកស្ពាន៧៧ និងតំបន់បង្កើតថ្មីនៃរមណីយដ្ឋានសំពៅជ្រៃ មានទំហំ៩៣ ហិកតា។

### ៤.២.១- តំបន់ទេសចរណ៍វប្បធម៌ និងសោភ័ណភាពទីប្រជុំជន

- ជំរុញ និងបង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជន ក្នុងការកសាងផលិតផលទេសចរណ៍រួមមាន ការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងទេសចរណ៍ផ្នែកធុរកិច្ច
- រៀបចំបែងចែកតំបន់សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន លំនៅឋានទេសចរណ៍
- កែលម្អ និងរៀបចំមហាវិថី វិថី អនុវិថី ផ្លូវសម្រាប់ដឹកជញ្ជូន និងផ្លូវថ្មើរជើង សម្រាប់មនុស្សទាំងអស់គ្នាដោយរៀបចំឱ្យមានផ្លូវសម្រាប់រថយន្ត កង់ ថ្មើរជើង និងបណ្តាញបៃតង ធានាបាននូវសោភ័ណភាព វប្បធម៌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ
- យកចិត្តទុកដាក់សុវត្ថិភាពចំណីអាហារ ដោយត្រូវជំរុញលើកកម្ពស់អនាម័យ ប្រព័ន្ធត្រួតពិនិត្យស្តង់ដា និងបញ្ហាជំងឺឆ្លងផ្សេងៗតាមរយៈចំណីអាហារ
- ធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសាធារណៈ ដើម្បីលុបបំបាត់ឱ្យបាននូវសកម្មភាពលួច ឆក់ ការបាត់បង់របស់របរភ្ញៀវ នៅតាមដងផ្លូវ កន្លែងកម្សាន្ត កន្លែងស្នាក់នៅ និងកន្លែងផ្សេងៗទៀត
- រៀបចំរមណីយដ្ឋានសំពៅជ្រៃឱ្យបានល្អប្រសើរដើម្បីបង្កើនការចាប់អារម្មណ៍ និងរក្សាបាននូវអត្តសញ្ញាណតំបន់
- ថែរក្សា និងការពារនូវសំណង់សម្រាប់បម្រើវិស័យវប្បធម៌ ប្រវត្តិសាស្ត្រ ដូចជាវត្តវាលស្បូវ វត្តសំពៅមាស បង្គោលព្រំដែនចាស់ និងប្រឡាយចំណុចដី១០០ ម៉ែត្រ ព្រមទាំងជំរុញឱ្យមានកិច្ចការពារ និងអភិរក្សឡើងវិញនូវទីតាំងទាំងនោះ។

### ៤.២.២- តំបន់ទេសចរណ៍ធម្មជាតិ

- ជំរុញការរៀបចំអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ និងទេសចរណ៍កែច្នៃនៅតាមដងទន្លេបាសាក់ ព្រែកស្ពាន៧៥ ព្រែកស្ពាន៧៦ និងព្រែកស្ពាន៧៧ សម្រាប់ទេសចរណ៍កម្សាន្ត ផ្លូវធ្លោបាយ ដឹកជញ្ជូន និងជាប្រភពផ្តល់ទឹកសម្រាប់ប្រើប្រាស់ជាទូទៅ
- រៀបចំចងក្រងសហគមន៍ទេសចរណ៍ អភិវឌ្ឍទេសចរណ៍ស្នាក់នៅ លើកទឹកចិត្តផលិតផលក្នុងស្រុក និងរៀបចំឱ្យមានការលក់ផលិតផលក្នុងកន្លែងកម្សាន្តនានា

- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ ចំណតទូក ផ្លាកសញ្ញាបង្ហាញផ្លូវទេសចរណ៍ និងប្រព័ន្ធការពារសុវត្ថិភាព
- រៀបចំតាមបណ្តោយដងទន្លេបាសាក់ ជាសួនច្បារ ជាតំបន់លម្ហែកម្សាន្ត និងកន្លែងទេសចរណ៍ធម្មជាតិ ដែលមានអនាម័យបរិស្ថានល្អ រក្សានូវលក្ខណៈដើមធម្មជាតិរបស់ទន្លេ និងព្រៃក និងផ្ទៃទឹកការពារ ដើម្បីទាក់ទាញភ្ញៀវទេសចរ
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានទេសចរណ៍ គេហទំព័រតំបន់ទេសចរណ៍ទាំងមូល ហើយចាំបាច់ត្រូវតភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ទាំងនៅក្នុងអនុតំបន់ និងតំបន់
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងវិស័យទេសចរណ៍ ដើម្បីលើកកម្ពស់ទំនិញសហគមន៍ តាមរយៈភូមិមួយផលិតផលមួយ និងបង្កើតភូមិផលិតកម្មបម្រើភ្ញៀវទេសចរទូទៅ
- យកចិត្តទុកដាក់ និងពង្រឹងសុវត្ថិភាព ប្រព័ន្ធ ឬមធ្យោបាយសង្គ្រោះបន្ទាន់ ជាពិសេសត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ ឬសង្គ្រោះបឋម សន្តិសុខការពារតាមរមណីយដ្ឋាន និងកន្លែងកម្សាន្ត ព្រមទាំងរៀបចំឱ្យមានការបំពាក់នូវសម្ភារសង្គ្រោះបន្ទាន់គ្រប់គ្រាន់។

### ៤.២.៣-ខ្សែទស្សនាកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍

ទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ មានសក្តានុពលផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ ការរស់នៅ និងបំពេញការងារ ដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ច សង្គមកិច្ចកើនឡើងឆាប់រហ័ស។ ទីប្រជុំជនជ្រៃធំ ចាំបាច់ទាញយកសក្តានុពលទេសចរណ៍ និងធម្មជាតិដែលត្រូវយកចិត្តទុកដាក់រៀបចំប្រែក្លាយជាគោលដៅទេសចរណ៍ ផ្សព្វផ្សាយទាក់ទាញទេសចរណ៍ រៀបចំយន្តការគ្រប់គ្រង និងអភិវឌ្ឍនៅនឹងកន្លែង ក្នុងនោះការប្រមូលផ្តុំចងក្រងជាសហគមន៍ទេសចរណ៍ ដោយផ្តល់លទ្ធភាព កសាងសមត្ថភាព ចំណេះដឹង និងបង្កើនការងារជូនប្រជាពលរដ្ឋមូលដ្ឋានឱ្យបានច្រើន គឺជាអាទិភាព។ ដូចនេះ អាជ្ញាធរស្រុក ឃុំ សង្កាត់ ស្ថាប័នមានសមត្ថកិច្ច និងអង្គភាពពាក់ព័ន្ធ ចាំបាច់ត្រូវយកចិត្តទុកដាក់÷

- រៀបចំ និងបង្កើតខ្សែទស្សនាកម្សាន្តទេសចរណ៍ ប្រកបដោយប្រសិទ្ធភាព
- កែលម្អ និងបង្កើតផលិតផលទេសចរណ៍ ឱ្យកាន់តែសម្បូរបែប
- កសាង កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងតម្រូវការចាំបាច់នានា ដើម្បីបម្រើសេវាកម្មទេសចរណ៍ឱ្យបានល្អប្រសើរ
- រៀបចំខ្សែទស្សនាកម្សាន្ត ជាលក្ខណៈកញ្ចប់ទេសចរណ៍នៃតំបន់ជ្រៃធំ ជាមួយនឹងតំបន់ផ្សេងៗទៀតដែលមានការចាប់អារម្មណ៍ខ្លាំងពីភ្ញៀវជាតិ និងអន្តរជាតិ។

### ៤.២.៤-ការអភិវឌ្ឍធនធានមនុស្ស

- ជំរុញការបណ្តុះបណ្តាលជំនាញដល់និយោជិកបម្រើការងារក្នុងវិស័យទេសចរណ៍ ដោយអនុវត្តតាមស្តង់ដាទេសចរណ៍
- រៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍទេសចរណ៍ តាមលក្ខណៈធម្មជាតិ និងកែច្នៃ
- រៀបចំបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកទេសទេសចរណ៍
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈទីប្រជុំជនជ្រៃធំលើវិស័យទេសចរណ៍
- ចលនាផ្នែកឯកជន ឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋានអាជីវកម្មជាក់ស្តែង
- ផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមកលើការគ្រប់គ្រង និងអភិវឌ្ឍវិស័យទេសចរណ៍។

## ៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម

ផ្តល់អាទិភាព និងលើកស្ទួយការកសាងផែនការហេដ្ឋារចនាសម្ព័ន្ធ ទៅតាមប្លង់គោល និងផែនការប្រើប្រាស់ដីដែលបានកំណត់ សម្រាប់បង្កភាពងាយស្រួលដល់ការអភិវឌ្ឍជាយុទ្ធសាស្ត្រនៅក្នុងតំបន់រួមមាន÷

### ៤.៣.១-អ័ក្សអភិវឌ្ឍន៍ទេសចរណ៍ ពាណិជ្ជកម្ម រាជធានីភ្នំពេញ ខេត្តកណ្តាល ភ្ជាប់ទៅអន្តរជាតិ

ផ្លូវជាតិមិត្តភាពកម្ពុជា-វៀតណាម និងកំណាត់ផ្លូវជាតិលេខ២១ ថ្មី ជាផ្លូវជាតិយ៉ាងសំខាន់ ដែលមានតួនាទី ជាអ័ក្សអភិវឌ្ឍន៍ទេសចរណ៍ ពាណិជ្ជកម្ម ចាំបាច់ត្រូវពង្រីកទទឹងផ្លូវមានស្រាប់ឱ្យមានទំហំពី៣០ ម៉ែត្រ ទៅ៦០ ម៉ែត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការដឹកជញ្ជូន ចរាចរណ៍ទូទៅ និងការធ្វើដំណើរ។ ក្រៅពីនេះ ចាំបាច់ត្រូវរៀបចំឱ្យមានផ្លូវជាតិមួយខ្សែទៀត ស្របនឹងផ្លូវជាតិលេខ២១ ដើម្បីកាត់បន្ថយការកកស្ទះ និងជួយសម្រួលដល់ចរាចរណ៍នៅពេលអនាគត ក្នុងបរិបទសេដ្ឋកិច្ច និងអត្រាប្រជាជនដែលកាន់តែមានកំណើនខ្ពស់។

### ៤.៣.២-ផ្លូវថ្នល់

- កសាងផ្លូវ និងស្ពាន ចំណតរថយន្តសាធារណៈ ប្រព័ន្ធផ្លូវក្រវាត់ទីប្រជុំជន ផ្លូវក្រវាត់ព្រំដែន និងកសាងផ្លូវទំនាក់ទំនងច្រកទ្វារអន្តរជាតិ ច្រកតំបន់ និងច្រករបៀងចាំបាច់មួយចំនួន
- ពង្រីក និងកែលម្អបណ្តាញផ្លូវ ស្ពាន និងលូ គ្រប់ប្រភេទឱ្យបានធំទូលាយសមរម្យ និងមានលក្ខណៈជាប្រព័ន្ធប្រទាក់ក្រឡាគ្នា ដើម្បីកាត់បន្ថយការកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍
- គ្រប់គ្រងផ្លូវ ស្ពាន ប្រព័ន្ធលូ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍ លើកទឹកចិត្តការប្រើរថយន្តសាធារណៈ និងរថយន្តប្រើថាមពលអគ្គិសនី ដើម្បីសន្សំសំចៃ ទប់ស្កាត់ការកកស្ទះចរាចរណ៍ និងការធានាបាននូវសុវត្ថិភាពតាមផងផ្លូវ
- ជួសជុល និងធ្វើថ្មី នៃផ្លូវឆ្ពោះទៅខ្សែក្រវាត់ព្រំដែន ស្ថិតនៅភូមិព្រែកស្បូវ និងភូមិជ្រៃធំ
- លើកទឹកចិត្តដៃគូឯកជន ចូលរួមកសាង ថែទាំ ជួសជុលផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

- លើកកម្ពស់ និងផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍តាមដងផ្លូវថ្នល់ ដូចជាផ្លាកសញ្ញា និងគំនូសសញ្ញា និងឈ្មោះផ្លូវនីមួយៗ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងផ្ដល់ភាពងាយស្រួលដល់ភ្ញៀវទេសចរ និងប្រជាពលរដ្ឋក្នុងការប្រើប្រាស់ និងធ្វើដំណើរទៅមក
- រៀបចំឱ្យមានភ្លើងសញ្ញាចរាចរណ៍ ភ្លើងបំភ្លឺតាមដងផ្លូវ ស្លាកសញ្ញា គំនូសសញ្ញាចរាចរណ៍ និងស្លាកលេខផ្លូវឱ្យបានគ្រប់ផ្លូវទាំងអស់
- រៀបចំឱ្យមានប្រព័ន្ធផ្លូវជាពហុជម្រើស និងមានចំណីផ្លូវ សួន និងលម្អបៃតងសមស្រប
- លើកកម្ពស់ និងផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍តាមផ្លូវគោក និងបណ្ដាញផ្លូវពាក់ព័ន្ធ។

### ៤.៣.៣-ផ្លូវទឹក

- រៀបចំប្រព័ន្ធដឹកជញ្ជូន និងមធ្យោបាយដឹកជញ្ជូនស្របតាមតម្រូវការក្នុងតំបន់
- សាងសង់ឱ្យមានកំពង់ផែ សម្រាប់ការលើកដាក់ និងដឹកជញ្ជូនទំនិញចេញចូល នៅច្រកទ្វារផ្លូវទឹក ទៅតាមបច្ចេកទេស និងស្តង់ដាអន្តរជាតិ
- រៀបចំ និងបង្កើនមធ្យោបាយទេសចរណ៍ផ្លូវទឹកឱ្យបានច្រើន ដើម្បីអូសទាញទេសចរណ៍ និងកំណើនសេដ្ឋកិច្ច
- ជីកប្រឡាយ និងស្ដារព្រែកដែលស្ថិតនៅក្នុងភូមិព្រែកស្បូវ ភូមិព្រែកស៊ីង និងភូមិជ្រៃធំ
- រៀបចំ និងកែលម្អប្រព័ន្ធផ្គត់ផ្គង់ទឹក ប្រព័ន្ធបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ
- រៀបចំអាងប្រព្រឹត្តកម្ម និងប្រព័ន្ធរំដោះទឹក ដើម្បីការពារបរិស្ថាន និងទប់ស្កាត់គ្រោះធម្មជាតិ។

### ៤.៣.៤-ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា

- ជំរុញ ស្ដារ និងអភិវឌ្ឍវិស័យថាមពលអគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ច ពាណិជ្ជកម្ម ឧស្សាហកម្ម និងលំនៅឋាន
- រៀបចំ និងទាក់ទាញអ្នកវិនិយោគលើផ្នែកឧស្សាហកម្ម អគ្គិសនី ថាមពលកំដៅថ្ងៃ ខ្យល់ រ៉ែ និងខ្សាច់ សម្រាប់ផ្គត់ផ្គង់ដល់សហគ្រាស និងតម្រូវការប្រើប្រាស់ផ្សេងៗ
- រៀបចំភ្លើងស្តុបបន្ថែមនៅតាមផ្លូវរង្វង់មូល ផ្លូវដែលមានចរាចរណ៍ច្រើន និងផ្លូវសំខាន់ៗ
- រៀបចំតបណ្ដាញអគ្គិសនីដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍទូទៅ និងផ្គត់ផ្គង់ជូនប្រជាពលរដ្ឋប្រើប្រាស់បានគ្រប់គ្រាន់។

### ៤.៣.៥-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌

- ជំរុញ ស្ដារ និងរៀបចំលម្អសាធារណៈនិងផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនា ដល់មនុស្សគ្រប់វ័យ រួមមាន កុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចាស់ និងជនពិការ ឱ្យទទួលបានការប្រើប្រាស់ប្រកបដោយសមធម៌

- រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនពិការ និងបង្គន់អនាម័យ សម្រាប់ជនពិការនៅតាមទីសាធារណៈ អគារសាធារណៈ និងកន្លែងផ្តល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ នៅគ្រប់កម្រិត តាមភូមិ និងតំបន់ក្នុងទីប្រជុំជនថ្មីធំ ស្របតាមអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យ ឱសថស្ថាន នៅតាមសង្កាត់ និងក្នុងទីប្រជុំជនស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល។

### ៤.៣.៦-ការផ្គត់ផ្គង់ទឹកស្អាត

#### ក)-ការផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជន

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវបានបង្កើតឡើងក្នុងទីប្រជុំជនថ្មីធំ សម្រាប់តម្រូវការនាពេលបច្ចុប្បន្ន និងនៅអនាគត។ កិច្ចការនេះ ត្រូវបានកែលម្អ ដើម្បីផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ទីប្រជុំជនថ្មីធំ ឱ្យបានល្អប្រសើរទៅតាមលំដាប់អាទិភាព ដូចខាងក្រោម÷

- សិក្សាពីជលសាស្ត្រ និងពិនិត្យតាមដានប្រភពទឹក ដើម្បីធានាបាននូវបរិមាណទឹកស្អាតសម្រាប់បរិភោគ និងទឹកសម្រាប់ប្រើប្រាស់ទូទៅ
- រៀបចំបទប្បញ្ញត្តិគ្រប់គ្រង និងវិធានការអនុវត្តជាក់ស្តែង ដើម្បីការពារប្រភពផ្គត់ផ្គង់ទឹកក្នុងការអភិវឌ្ឍទីប្រជុំជន និងការពង្រីកទីប្រជុំជននាពេលអនាគត
- ស្តារឡើងវិញ និងដោះដូរបំពង់ទឹកចាស់ៗ ដើម្បីកាត់បន្ថយការលេចធ្លាយ និងបង្កើនគុណភាពទឹក ព្រមទាំងលើកទឹកចិត្តបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកឱ្យបានគ្រប់ភូមិ
- ពង្រីកបណ្តាញចែកចាយទឹក ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជនឱ្យបានច្រើនជាងមុនក្នុងការប្រើប្រាស់ និងអភិវឌ្ឍន៍នានា ដើម្បីបង្កើនប្រាក់ចំណូលតាមគ្រួសារ និងបង្កើនថវិកាជាតិ
- ការពារ ពង្រីកបន្ថែម សាងសង់អាងស្តុកទឹក និងបណ្តាញចែកចាយទឹក ដើម្បីធានាការផ្គត់ផ្គង់ស្របតាមការរីកចម្រើន
- បន្តពង្រឹងសមត្ថភាព និងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកស្របតាមបទដ្ឋានបច្ចេកទេស និងតាមគម្រោងផែនការអនុវត្តជាក់ស្តែង។

#### ខ)-ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ក្រៅទីប្រជុំជន

ប្រភពទឹកនៅតំបន់ជុំវិញទីប្រជុំជនថ្មីធំ ក្នុងឃុំសំពៅពូន ត្រូវបានរៀបចំ និងគ្រប់គ្រងដូចខាងក្រោម÷

- ការពារប្រភពទឹកធម្មជាតិ ដែលមានស្រាប់ឱ្យបានល្អប្រសើរ
- ស្តារ និងកែលម្អអាងស្តុកទឹក និងបណ្តាញចែកចាយទឹកដែលមានស្រាប់ ដើម្បីអភិវឌ្ឍន៍ និងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ និងសម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ
- សិក្សា សាងសង់អាងស្តុកទឹក បង្កើនប្រភពផ្គត់ផ្គង់ទឹក និងពង្រីកបណ្តាញចែកចាយទឹក។

### ៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងការផ្សព្វផ្សាយផលិតផលក្នុងស្រុក

ដើម្បីជំរុញឱ្យមានផលប្រយោជន៍ពីវិស័យកសិកម្មដល់ប្រជាជនមូលដ្ឋានកាន់តែច្រើន គឺចាំបាច់ត្រូវ÷

- ផ្សព្វផ្សាយការងារផលិតកម្មកសិកម្មក្នុងទីប្រជុំជនជ្រៃធំ និងឃុំទាំងមូលឱ្យបានទូលំទូលាយ
- អប់រំប្រជាពលរដ្ឋក្នុងការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វល្អិត តាមស្តង់ដាបច្ចេកទេសត្រឹមត្រូវ
- អភិវឌ្ឍកសិកម្មតាមតម្រូវការទីផ្សារ និងការផ្គត់ផ្គង់ស្បៀងអាហារប្រចាំថ្ងៃរបស់ប្រជាជន
- រៀបចំទីផ្សារសម្រាប់ដោះដូរទំនិញ និងកសិផលរបស់ប្រជាពលរដ្ឋ ក្នុងស្រុក និងក្រៅប្រទេស
- ជំរុញយុទ្ធនាការភូមិមួយផលិតផលមួយ និងការប្រលងប្រណាំងឈានមុខ ក្នុងការអភិវឌ្ឍជាតិ
- បង្កើនគុណភាពផលិតផល និងផ្សព្វផ្សាយអំពីផលិតផលចម្រុះ ដែលផលិតដោយកសិករនៅមូលដ្ឋាន ឬអ្នកជំនួញក្នុងស្រុកក្រោមស្លាកពាណិជ្ជកម្ម ក្នុងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងលក់ផលិតផលទាំងនេះទៅអតិថិជន និងពង្រីកទីផ្សារឱ្យសម្បូរបែប
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចជនបទទៅក្នុងវិស័យទេសចរណ៍ ដើម្បីលើកកម្ពស់ទំនិញសហគមន៍តាមរយៈភូមិមួយផលិតផលមួយ និងបង្កើតភូមិផលិតកម្មបម្រើភ្ញៀវទេសចរទូទៅ
- សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីលុបបំបាត់ឱ្យបាននូវសកម្មភាពកសិកម្មប៉ះពាល់ដល់ធនធានធម្មជាតិ និងការប្រើប្រាស់ជីនិងថ្នាំគីមីមិនគោរពតាមស្តង់ដារបច្ចេកទេស
- អភិវឌ្ឍធនធានមនុស្ស ដោយជំរុញការបណ្តុះបណ្តាលជំនាញដល់កសិករ ដោយអនុវត្តតាមស្តង់ដាកសិកម្ម និងចលនាផ្ទែកឯកជនឱ្យចូលរួមបណ្តុះបណ្តាលទូលំទូលាយនៅតាមមូលដ្ឋាន។

### ៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

- ដោះស្រាយសំណង់បណ្តោះអាសន្ននៅលើដីសាធារណៈ និងដីឯកជនរបស់រដ្ឋ ដូចជាដីចំណីផ្លូវ ចំណីទន្លេ ចំណីព្រែក ពិសេសនៅតាមដងទន្លេបាសាក់ ព្រែកជ្រៃធំ ព្រែក៧៥ ព្រែក៧៦ និងព្រែក៧៧
- ដោះស្រាយសំណង់បណ្តោះអាសន្នស្របតាមសារាចរលេខ០៣.សរ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ក្រុង និងទីប្រជុំជន
- រៀបចំសួនច្បារ និងផ្ទៃបៃតងនៅតាមមន្ទីរពេទ្យ វត្តអារាម សាលារៀន អង្គភាព និងស្ថាប័ននានាដើម្បីឆ្លើយតបតាមតម្រូវការរស់នៅ និងការបំពេញការងារប្រកបដោយសុខដុមភាព។

### ៤.៦- យុទ្ធសាស្ត្រការពារបរិស្ថាន និងធនធានធម្មជាតិ

ដើម្បីលើកកម្ពស់និរន្តរភាពបរិស្ថាន និងការទាក់ទាញលើការអភិវឌ្ឍ ក្នុងតំបន់ទីប្រជុំជនជ្រៃធំ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ចាំបាច់ត្រូវ÷

#### ៤.៦.១- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង

- បង្កើតយន្តការអនុវត្ត និងហេដ្ឋារចនាសម្ព័ន្ធសមស្រប ក្នុងការគ្រប់គ្រងសំណល់រឹង
- អភិវឌ្ឍបច្ចេកវិជ្ជាទំនើបក្នុងការសំណល់រឹងបច្ចុប្បន្ន និងរៀបចំផែនការអនាគតច្បាស់លាស់
- ជំរុញការចូលរួមពីប្រជាពលរដ្ឋ និងការវិនិយោគរបស់វិស័យឯកជនក្នុងគ្រប់គ្រងសំណល់រឹង
- រៀបចំឱ្យមានមូលនិធិថែទាំបរិស្ថាន និងជំរុញការវិនិយោគវិស័យឯកជន និងសហការអភិវឌ្ឍ
- រៀបចំទីតាំងទុកដាក់សំរាមបណ្តោះអាសន្ននៅតាមបណ្តាផ្សារទាំងអស់ឱ្យបានសមរម្យ
- រៀបចំទីតាំងចាក់ និងកែច្នៃសំរាមតាមស្តង់ដាបច្ចេកទេស មានលក្ខណៈធំទូលាយ និងល្អប្រសើរ
- ជំរុញឱ្យមានការអនុវត្តគោលការណ៍ កាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ លើការគ្រប់គ្រងសំណល់រឹង
- រៀបចំមធ្យោបាយប្រមូលសំណល់រឹង និងរៀបចំទីតាំងសម្រាប់សំណល់រឹង ស្របតាមបទដ្ឋានបច្ចេកទេស និងស្តង់ដាទីប្រជុំជនស្អាត។

#### ៤.៦.២- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ

- ផ្សព្វផ្សាយគោលការណ៍បរិស្ថាន និងអនាម័យ ដើម្បីធានាបានគុណភាពបរិស្ថានក្នុងទីប្រជុំជន
- លើកកម្ពស់ការធ្វើផែនការអភិវឌ្ឍន៍ដោយយកចិត្តទុកដាក់ដល់បរិស្ថាន និងការរស់នៅ
- រៀបចំ និងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលទៅបឹង ទន្លេ និងព្រែកនានា
- រៀបចំប្រព័ន្ធបង្ហូរទឹកភ្លៀង និងស្ថានីយបូមទឹក ដើម្បីការពារទឹកជំនន់ និងសម្រាប់ផ្គត់ផ្គង់ទឹក
- ជំរុញឱ្យមានគោលការណ៍កែច្នៃបច្ចេកវិជ្ជាទំនើប ដើម្បីប្រើប្រាស់ឡើងវិញនូវកាកសំណល់រាវ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម កាស៊ីណូ សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈត្រូវមានអាងប្រព្រឹត្តិកម្ម និងអាងចម្រោះទឹកកខ្វក់តាមស្តង់ដា
- កាត់បន្ថយការបំពុលទឹក តាមរយៈការបង្កើតប្រព័ន្ធបង្ហូរទឹក និងការរៀបចំអាងប្រព្រឹត្តិកម្មសំណល់រាវ ជាពិសេសនៅតាមទីផ្លាសាធារណៈ និងតំបន់លំនៅឋាននានា
- កាត់បន្ថយការបូមយកទឹកក្រោមដីរបស់ឯកជន តាមរយៈការពង្រីក និងជំរុញឱ្យមានការប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ និងចែកចាយទឹកតាមបច្ចេកទេសថ្មី
- រៀបចំប្រព័ន្ធគ្រប់គ្រងកាកសំណល់រាវប្រកបដោយប្រសិទ្ធភាព និងទប់ស្កាត់ការបំពុលបរិស្ថានបណ្តាលមកពីរោងចក្រ សហគ្រាស សិប្បកម្ម និងអាជីវកម្មទាំងឡាយ។

### ៤.៦.៣-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

- តំបន់ទេសចរណ៍វប្បធម៌វត្តព្រែកស្បូវ វត្តសំពៅមាស ព្រះវិហារ និងសាលារៀន
- តំបន់សួនកម្សាន្ត និងផ្ទៃបៃតងតាមដងទន្លេបាសាក់ ព្រែកជ្រៃធំ ព្រែក៧៥ ព្រែក៧៦ និងព្រែក៧៧
- តំបន់អមសងខាងផ្លូវជាតិលេខ២១ និងកំណាត់ផ្លូវជាតិលេខ២១ ថ្មី ក្នុងតំបន់ជ្រៃធំ
- តំបន់ច្រកទ្វារអន្តរជាតិផ្លូវគោក និងផ្លូវទឹក នៅជិតព្រំដែនវៀតណាម
- តំបន់ជុំវិញស្ពានមិត្តភាពកម្ពុជា វៀតណាម ជ្រៃធំ ឡុងប៊ិន និងស្ពាននៃព្រែក៧៥ ព្រែក៧៦ និងព្រែក៧៧
- តំបន់បង្កើតថ្មីនៃគម្រោងទេសចរណ៍ និងរមណីយដ្ឋានសំពៅទឹក
- តំបន់ទាំងឡាយជាផ្លូវ និងចំណីផ្លូវ នៃទីប្រជុំជនជ្រៃធំ។

### ៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារ និងថែរក្សាជីវចម្រុះក្នុងទន្លេបាសាក់ ព្រែកទាំងឡាយ និងផ្ទៃទឹក សម្រាប់ជាកន្លែងត្រីពង-កូន ឬកន្លែងរកចំណីសម្រាប់ធនធានវារិជាត និងប្រភេទត្រីជាច្រើន
- កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីន តាមរយៈការផ្គត់ផ្គង់អគ្គិសនីឱ្យបានគ្រប់គ្រាន់ លើកកម្ពស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថាន និងប៉ះពាល់សណ្តាប់ធ្នាប់
- កាត់បន្ថយការបូមទឹកក្រោមដីរបស់ឯកជន តាមរយៈការពង្រីក និងជំរុញឱ្យមានការប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មីក្នុងទីប្រជុំជនជ្រៃធំ ប្រកបដោយប្រសិទ្ធភាព
- ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងការសាងសង់នៃគម្រោងអភិវឌ្ឍន៍ និងវិនិយោគនានា
- បង្កើតគណៈកម្មាធិការ និងក្រុមការងារត្រួតពិនិត្យបរិស្ថានប្រកបដោយប្រសិទ្ធភាព និងការលើកកម្ពស់ចំណេះដឹងរបស់ប្រជាជន និងអ្នកអភិវឌ្ឍន៍អំពីបរិស្ថានឱ្យបានទូលំទូលាយ
- រៀបចំមូលនិធិថែទាំបរិស្ថានក្នុងទីប្រជុំជន ដោយជំរុញការវិនិយោគវិស័យឯកជន និងរដ្ឋ។

## ៤.៧-យុទ្ធសាស្ត្រអភិវឌ្ឍន៍ពាណិជ្ជកម្ម

- បែងចែកជាតំបន់សម្រាប់ការវិនិយោគពាណិជ្ជកម្មបច្ចុប្បន្ន និងទៅអនាគតឱ្យបានជាក់លាក់ និងត្រឹមត្រូវ និងរៀបចំឱ្យមានគោលនយោបាយទាក់ទាញវិនិយោគសមស្រប
- កែលម្អ និងពង្រីកទីផ្សារលក់ដូរ ដើម្បីឱ្យប្រជាពលរដ្ឋ និងអាជីវករក្នុងផ្សារមានកន្លែងលក់ដូរធំទូលាយសមស្រប និងមានសណ្តាប់ធ្នាប់ល្អ

- កែលម្អទីផ្សារមានស្រាប់ទាំងឯកជន និងសាធារណៈ ឱ្យមានលក្ខណៈស្តង់ដា រួមមានចំណតយានយន្ត ច្រកដើរក្នុងផ្សារ បណ្តាញទឹក ភ្លើង តំបន់ផ្ទៃបៃតង ហេដ្ឋារចនាសម្ព័ន្ធកម្សាន្ត ឱ្យមានរបៀបរៀបរយ និងសណ្តាប់ធ្នាប់ល្អ។ រៀបចំថ្មី ឬកែលម្អផ្សារលក់ដូរដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវរបស់ប្រជាពលរដ្ឋ
- លើកទឹកចិត្តឱ្យមានការវិនិយោគ ដោយបង្កើតជាផ្សារទំនើប ហាងទំនិញ ផ្សាររាត្រី និងមជ្ឈមណ្ឌលពាណិជ្ជកម្ម ធនាគារ ឃ្លាំង សហគ្រាសផ្សេងៗ ដើម្បីងាយស្រួលក្នុងការដោះដូរទំនិញ បង្កើតការងារ និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច
- រៀបចំបង្កើតឃ្លាំងស្តុកទំនិញ សម្រាប់ចែកចាយទៅរាជធានីភ្នំពេញ ឆ្លងដែនទៅវៀតណាម និងតំបន់ជុំវិញ ព្រមទាំងរៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យបានល្អ ដើម្បីជួយសម្រួលដល់ការដឹកជញ្ជូន
- បង្កើនការរៀបចំកម្មវិធីតាំងពិព័រណ៍ពាណិជ្ជកម្ម និងផ្សព្វផ្សាយផលិតផលគ្រប់ប្រភេទ ដើម្បីបង្កើនការផលិត និងជំរុញសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងទីប្រជុំជនឱ្យបានខ្លាំងក្លា
- លើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យមានផលិតផលកែច្នៃក្នុងស្រុក និងរៀបចំបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មខ្នាតតូច មធ្យម និងធំ ដើម្បីសមតុល្យក្នុងការនាំចេញនាំចូលទំនិញ
- បង្កើតឱ្យមានភោជនីយដ្ឋាន ក្លឹបកម្សាន្ត និងសេវាកម្មសម្បូរបែប ដើម្បីឆ្លើយតបតាមតម្រូវការរបស់អតិថិជន និងការទាក់ទាញការវិនិយោគ។

## ៤.៨- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

- រៀបចំបែងចែកជាតំបន់ឧស្សាហកម្មធុនស្រាល និងសិប្បកម្មឱ្យបានសមស្រប និងមានទីតាំងនៅដាច់ចេញពីតំបន់លំនៅឋាន
- លើកទឹកចិត្តដល់អ្នកវិនិយោគជាតិ និងអន្តរជាតិដែលមកធ្វើឧស្សាហកម្មផ្ទៃបៃតងទីប្រជុំជនជ្រៃធំ
- បង្កើនស្ទួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យម សំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំក្រៅប្រទេស និងសហគ្រាសក្នុងស្រុក ពិសេសការចូលរួមក្នុងខ្សែចង្វាក់តម្លៃ និងខ្សែចង្វាក់ផលិតកម្មតំបន់ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់
- ជំរុញការអភិវឌ្ឍឧស្សាហកម្មធុនស្រាល ដែលប្រើគ្រឿងម៉ាស៊ីនស្វ័យប្រវត្តិទំនើប សម្រាប់កែច្នៃផលិតផលកសិកម្ម និងសម្ភារប្រើប្រាស់ផ្សេងៗ ដើម្បីបំពេញនូវតម្រូវការប្រជាពលរដ្ឋក្នុងទីប្រជុំជន និងសម្រាប់ចែកចាយទាំងក្នុង និងក្រៅប្រទេស
- លើកទឹកចិត្តដល់ការវិនិយោគរោងចក្រកាត់ដេរ សហគ្រាស រោងចក្រដំឡើងយានយន្ត និងគ្រឿងអេឡិចត្រូនិក សិប្បកម្មដែលអាចបង្កើតការងារជូនប្រជាពលរដ្ឋ ដើម្បីលើកស្ទួយជីវភាពរស់នៅ និងការរីកចម្រើននៅក្នុងតំបន់

- ផ្លាស់ប្តូរទីតាំងរោងចក្រ សហគ្រាស សិប្បកម្ម ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្មបច្ចុប្បន្ន ដែលប៉ះពាល់ដល់បរិស្ថាន និងសុខភាពប្រជាពលរដ្ឋ ដោយសាងសង់ ឬកែសម្រួលឡើងវិញស្របតាមស្តង់ដាបច្ចេកទេស និងប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ
- លើកកម្ពស់ការប្រកួតប្រជែងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈវិស័យឧស្សាហកម្ម និងលើកទឹកចិត្តដល់អង្គភាពដែលមានស្នាដៃល្អ
- ជំរុញការអភិវឌ្ឍឧស្សាហកម្មដែលប្រើប្រាស់បច្ចេកវិជ្ជាទំនើប ក្នុងតំបន់អភិវឌ្ឍន៍ព្រំដែនជ្រៃធំ ដើម្បីលើកកម្ពស់សេដ្ឋកិច្ច និងកិច្ចការពារបរិស្ថាន។ អូសទាញ និងលើកទឹកចិត្តដល់ឧស្សាហកម្មដែលមានទិសដៅនាំចេញ
- បង្កើតមូលនិធិសម្រាប់វិស័យឧស្សាហកម្ម និងជំរុញការបង្កើនវត្ថុធាតុដើមក្នុងស្រុក ដើម្បីធានាបាននិរន្តរភាពការផលិត និងការនាំចេញ។

## ៤.៩- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ

- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្សទេសភាពវប្បធម៌ និងធម្មជាតិជុំវិញ ដោយសិក្សានិងរៀបចំផែនការគ្រប់គ្រងការប្រើប្រាស់ទឹកក្រោមដី និងការប្រើប្រាស់ដីធ្លីសមស្រប
- រៀបចំ ស្តារ និងពង្រីកការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនឱ្យបាន១០០% តាមរយៈអង្គភាពរដ្ឋាករស្វយ័តក្នុងតំបន់ ដើម្បីបញ្ឈប់ការបូមទឹកក្រោមដីរបស់វិស័យឯកជន ដែលអាចនាំឱ្យបរិមាណទឹកក្រោមដីថយចុះ និងអាចបង្កឱ្យមានការបាក់ច្រាំងទន្លេ ព្រែក ទំនប់
- សិក្សាចរន្តទឹក ប្រភពទឹកទន្លេ ព្រែក និងរបបទឹកភ្លៀង ទឹកជំនន់ ដើម្បីធានាបានសុវត្ថិភាពដល់ការរស់នៅក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព
- សិក្សា និងរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធសមស្រប ដើម្បីឆ្លើយតបទៅនឹងផែនការអភិវឌ្ឍន៍និងការទប់ស្កាត់គ្រោះមហន្តរាយ ដែលអាចកើតឡើងជាយថាហេតុ
- សិក្សាពីបម្រែបម្រួលអាកាសធាតុ ដែលធ្វើឱ្យកើនឡើងកម្តៅ និងធ្វើឱ្យរបបទឹក កម្ពស់ទឹកភ្លៀងមិនទៀងទាត់ នាំឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ និងការអភិវឌ្ឍលើគ្រប់វិស័យ
- អភិវឌ្ឍច្រាំងព្រែកជ្រៃធំ ទន្លេបាសាក់ ព្រែក៧៥ ព្រែក៧៦ និងព្រែក៧៧ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីការពារដីធ្លី និងទប់ស្កាត់គ្រោះមហន្តរាយ ដែលអាចកើតឡើង
- អនុវត្តតាមច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ និងពង្រឹងការអនុវត្តបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ៤.១០- យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅតាមមូលដ្ឋាន

ការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន ជាកត្តាសំខាន់ចាំបាច់ និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច អភិវឌ្ឍទីប្រជុំជន និងបរិស្ថាន ដូចជា÷

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្ត និងគម្រោងដែលត្រូវស្នើឡើងក្នុងខេត្ត
- ពង្រឹងមូលដ្ឋានធនធានមនុស្សទាំងនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ពិសេសការគ្រប់គ្រងអភិវឌ្ឍន៍ និងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតអភិវឌ្ឍដី ការចុះបញ្ជីយានយន្ត ការបូមទឹកក្រោមដីរបស់ឯកជន និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋាន តាមរយៈការប្រមូលចំណូលនៅមូលដ្ឋាន ការបែងចែកចំណូលរដ្ឋពីវិស័យទេសចរណ៍ និងប្រភពផ្សេងៗទៀត ដល់រដ្ឋបាលមូលដ្ឋាន សម្រាប់ការប្រើប្រាស់ជាប្រយោជន៍សាធារណៈ ជាពិសេសការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការលើកកម្ពស់សោភ័ណភាព និងបរិស្ថានក្នុងទីប្រជុំជន
- បង្កើនកិច្ចសហប្រតិបត្តិការទូលំទូលាយលើគ្រប់វិស័យ ជាមួយភាគីមិត្តដែលនៅជាប់ព្រំដែន។

### ៤.១១- យុទ្ធសាស្ត្រការពារព្រំដែន

ដើម្បីរក្សានូវសន្តិភាព បូរណភាពទឹកដី និងការអភិវឌ្ឍ សេដ្ឋកិច្ច សង្គម នៅតាមព្រំដែន និងកិច្ចការពារបរិស្ថានកម្ពុជា-វៀតណាម តាមរយៈច្រកសេដ្ឋកិច្ចអន្តរជាតិជ្រៃធំ ចាំបាច់រៀបចំនូវយុទ្ធសាស្ត្រសំខាន់ៗរួមមាន÷

- ការគ្រប់គ្រង ការពារបូរណភាពទឹកដីតំបន់ព្រំដែនទឹក និងដីគោក ព្រមទាំងផ្សារភ្ជាប់ទំនាក់ទំនងល្អរវាងប្រទេសទាំងពីរកម្ពុជា-វៀតណាម និងរវាងទីប្រជុំជនទាំងពីរ ប្រកបដោយគុណភាព ប្រសិទ្ធភាព ចីរភាព និងសមធម៌
- កំណត់បង្គោលសីមារវាងប្រទេសទាំងពីរឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ ដោយឈរលើគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិដែលមានជាធរមាន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម ចាំបាច់គ្រប់ប្រភេទ ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋ និងគ្រួសារកងទ័ពខ្មែរទៅរស់នៅ និងប្រកបការងារនៅតាមព្រំដែនឱ្យបានកាន់តែច្រើនឡើង
- រៀបចំកងកម្លាំងឈរជើងការពារព្រំដែនរឹងមាំ ទាំងកងទ័ព កងរាជអាវុធហត្ថ និងនគរបាល
- បំពាក់រាល់ឧបករណ៍ និងសម្ភារទំនើបៗ ដល់កងកម្លាំង និងក្រុមអ្នកបច្ចេកទេសការពារព្រំដែនឱ្យបានគ្រប់គ្រាន់ និងមានគុណភាពខ្ពស់។

## ៥- ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗ ដូចតទៅ÷

### ៥.១- ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម

តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកកោះធំ បទប្បញ្ញត្តិនគរូបនីយកម្ម ដែលត្រូវរៀបចំ រួមមាន÷

- ផែនការប្រើប្រាស់ដីក្នុងឃុំ និងផែនការប្រើប្រាស់ដីលម្អិតនៃតំបន់ជ្រែធំ
- ប្លង់លម្អិតនគរូបនីយកម្ម និងបទដ្ឋានបច្ចេកទេស សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍
- ផែនទីកំណត់កម្ពស់អគារ និងសន្ទស្សន៍ប្រើប្រាស់ដីតាមតំបន់ជាក់ស្តែង
- ផែនទីកំណត់ទីតាំងលម្ហសាធារណៈ ផ្ទៃបៃតង ផ្លូវថ្នល់ កំពង់ផែ ព្រែក បឹងបួរ ទំនប់ទឹក ប្រឡាយទឹក ប៉ុស្តិ៍ ស្ថានីយ។ល។
- ផែនទីតំបន់កម្រិតការសាងសង់ និងតំបន់អាចសាងសង់បាន ដែលធានាបាននូវប្រសិទ្ធភាព
- ណែនាំការអនុវត្តបទប្បញ្ញត្តិតាមតំបន់ប្រើប្រាស់ដី និងផែនការហេដ្ឋារចនាសម្ព័ន្ធ
- ប្រព័ន្ធគ្រប់គ្រងដីធ្លី សំណង់ និងប្លង់អភិវឌ្ឍន៍តាមតំបន់នីមួយៗនៃប្លង់គោលទីប្រជុំជនជ្រែធំ។

### ៥.២- ការផ្សព្វផ្សាយ

រៀបចំប្រជុំផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រែធំនេះដល់ក្រុមជំនាញ វិនិយោគិន និងប្រជាពលរដ្ឋ តាមរយៈគេហទំព័រ ឬតាមបណ្តាញសង្គមក្នុងប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋបាលស្រុក ខេត្ត និងផ្សេងៗ។

### ៥.៣- ការអនុវត្តគម្រោងតាមវិស័យ

គម្រោងសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍ ការគ្រប់គ្រងបរិស្ថាន ទេសចរណ៍ កសិកម្ម និងការផ្សព្វផ្សាយផលិតផល ការដឹកជញ្ជូន ធនធានទឹកនិងការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់រឹង ប្រព័ន្ធលូបង្ហូរទឹកភ្លៀងនិងសំណល់រាវ ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍ មានដូចខាងក្រោម÷

#### ៥.៣.១- ការអភិវឌ្ឍទីប្រជុំជន

- កំណត់ព្រំប្រទល់ភូមិ និងរៀបចំប្លង់គ្រប់គ្រងលម្អិតតាមភូមិនិងប្លុកនីមួយៗក្នុងទីប្រជុំជន
- ដាក់លេខផ្ទះ លេខផ្លូវ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាល និងទំនាក់ទំនងអាសយដ្ឋាន
- កសាងសមត្ថភាពមន្ត្រី និងជំនាញការគ្រប់គ្រង និងអនុវត្តផែនការលំនៅឋាននិងទីប្រជុំជន
- ធ្វើផែនការអភិវឌ្ឍលម្អិតតាមតំបន់លំនៅឋាន ពាណិជ្ជកម្ម ទេសចរណ៍ និងតំបន់ផ្សេងៗ
- កែលម្អសោភ័ណភាព ទេសភាព និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៃតំបន់ទីប្រជុំជន។

#### ៥.៣.២- អភិវឌ្ឍន៍វិស័យទេសចរណ៍

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងរៀបចំគម្រោងអាទិភាព ដើម្បីសម្រួលដល់ការធ្វើដំណើរក៏ដូចជាការទាក់ទាញភ្ញៀវទេសចរ
- លើកកម្ពស់គុណភាពនៃការគ្រប់គ្រងទេសចរណ៍ តាមរយៈភាពជាដៃគូរវាងរដ្ឋ និងឯកជន

- លើកកម្ពស់ការបង្កើតសហគមន៍ទេសចរណ៍ និងសហការទូលំទូលាយផ្នែកទេសចរណ៍
- អភិវឌ្ឍ និងលើកកម្ពស់ទេសចរណ៍តាមភូមិ និងទេសចរណ៍តាមបែបធម្មជាតិ និងកែច្នៃ
- សិក្សាលម្អិតអំពីលទ្ធភាពទទួលភ្ញៀវទេសចរ និងការគ្រប់គ្រងរមណីយដ្ឋាន
- ផ្គត់ផ្គង់ប្រព័ន្ធអគ្គិសនី សម្រាប់ប្រើប្រាស់ក្នុងតំបន់ទេសចរណ៍
- លើកកម្ពស់ទេសចរណ៍គុណភាពតាមរយៈភាពជាដៃគូរវាងរដ្ឋ-ឯកជន -គម្រោងអាទិភាព
- បណ្ដុះបណ្ដាលមគ្គុទេសក៍ទេសចរណ៍ និងការផ្ដល់លិខិតអនុញ្ញាត និងការលើកទឹកចិត្ត
- សិក្សាលម្អិតអំពីលទ្ធភាពទទួលភ្ញៀវទេសចរ និងការគ្រប់គ្រងរមណីយដ្ឋានឱ្យបានល្អ។

**៥.៣.៣-ការដឹកជញ្ជូន**

- កែសម្រួល និងកសាងផ្លូវក្រវាត់ព្រំដែន ចាប់ពីក្បាលជ្រោយដងទន្លេបាសាក់រហូតដល់ដី១០០ ម៉ែត្រ និងពីដី១០០ ម៉ែត្ររហូតដល់ព្រំប្រទល់ខេត្តតាកែវ
- កែសម្រួល និងកសាងផ្លូវពីចំណុចផ្លូវជាតិលេខ២១ រហូតដល់វត្តព្រែកស្បូវ និងឆ្ពោះទៅព្រំដែន១០០ ម៉ែត្រ និងព្រំប្រទល់ខេត្តតាកែវ
- ស្ដារ និងកសាងបណ្ដាញផ្លូវក្នុងទីប្រជុំជនចាស់ និងថ្មី ទៅតាមតំបន់នីមួយៗ
- លើកកម្ពស់ស្ថាប័ន និងយុទ្ធនាការសម្រាប់ការពារសុវត្ថិភាពតាមផ្លូវថ្នល់
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធផ្លូវថ្មីដែលមានទំនាក់ទំនងជាមួយផ្លូវជាតិលេខ២១ និងកំណាត់ផ្លូវជាតិលេខ២១ថ្មី និងការបង្កើតឱ្យមានរង្វង់មូល៤ ដើម្បីជួយសម្រួលចរាចរណ៍ និងរក្សាសោភ័ណភាពទីប្រជុំជន
- ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព។

**៥.៣.៤-ការអភិវឌ្ឍន៍តំបន់ពាណិជ្ជកម្ម**

- កសាងផ្លូវ ស្ពាន និងលូ សម្រាប់ការអភិវឌ្ឍ និងសម្រួលដល់ការដឹកនាំទំនិញចេញចូល
- ផ្គត់ផ្គង់ប្រព័ន្ធអគ្គិសនី សម្រាប់ប្រើប្រាស់ក្នុងតំបន់ពាណិជ្ជកម្ម ដូចជាការបំភ្លឺ និងផ្ដល់ថាមពលដល់ការលើកដាក់ទំនិញ និងការប្រើប្រាស់ទូទៅ
- កសាងផ្សារ និងមជ្ឈមណ្ឌលពាណិជ្ជកម្ម សម្រាប់លក់ដោះដូរទំនិញ និងឃ្លាំងសម្រាប់ស្ដុក និងរក្សាទុកទំនិញ
- កសាងច្រកទ្វារព្រំដែនអន្តរជាតិផ្លូវគោក និងផ្លូវទឹក ដើម្បីគ្រប់គ្រងការចេញចូលតាមព្រំដែន។

**៥.៣.៥-ការគ្រប់គ្រងបរិស្ថាន**

- ពង្រឹងសមត្ថភាពស្ថាប័ន និងលើកកម្ពស់ការយល់ដឹងពីបរិស្ថាន
- ប្រែក្លាយទីប្រជុំជនជ្រៃធំ ជាទីក្រុងមួយដែលមានលក្ខណៈល្អប្រសើរសម្រាប់ការរស់នៅ និងការអភិវឌ្ឍលើគ្រប់វិស័យ

- បង្កើនតំបន់លម្ហែកម្សាន្ត តំបន់ផ្ទៃបៃតង និងលម្ហសាធារណៈ នៅតាមដងទន្លេបាសាក់ និងតាមស្ពានព្រែក៧៥ ព្រែក៧៦ និងព្រែក៧៧
- គ្រប់គ្រងការងារបរិស្ថាន និងបង្កើតសេវានិងមូលនិធិផ្នែកបរិស្ថាន
- អនុវត្តតាមក្រមបរិស្ថាន និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**៥.៣.៦- ការគ្រប់គ្រងធនធានទឹក និងផ្គត់ផ្គង់ទឹកស្អាត**

- គ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់បណ្ដាញផ្គត់ផ្គង់ទឹកស្អាតប្រកបដោយប្រសិទ្ធភាព
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ ដែលមានគុណភាពស្តង់ដាខ្ពស់
- អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មី តាមតម្រូវការនៃការអភិវឌ្ឍលើគ្រប់វិស័យ
- កសាងអាងប្រព្រឹត្តកម្មទឹកកខ្វក់ និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងទីប្រជុំជនជ្រៃធំ។

**៥.៣.៧- ការគ្រប់គ្រងប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ**

- លើកកម្ពស់ការរៀបចំ និងកសាងប្រព័ន្ធបង្ហូរទឹកក្នុងទីប្រជុំជនជ្រៃធំឱ្យបានល្អប្រសើរ
- បង្កើតស្ថានីយបូមទឹកចេញចូល ដើម្បីផ្គត់ផ្គង់តម្រូវការទឹក និងការពារការលិចលង់
- អភិវឌ្ឍ និងកែលម្អប្រព័ន្ធបង្ហូរទឹកក្នុងទីប្រជុំជនចាស់និងថ្មី ដើម្បីធានាដល់បរិស្ថាននៃការរស់នៅ ការធ្វើអាជីវកម្ម និងបំពេញការងារ
- គ្រប់គ្រងសំណល់រាវ ពិសេសសំណល់រាវចេញពីតំបន់លំនៅឋាន ឧស្សាហកម្ម និងផ្សេងៗ
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រជាពលរដ្ឋនូវរបៀបគ្រប់គ្រង និងប្រើប្រាស់សំណល់រាវ។

**៥.៣.៨- ការគ្រប់គ្រងសំណល់រឹង**

- បង្កើនសេវាកម្មគ្រប់គ្រងសំណល់រឹង តំបន់ដែលទទួលបានសេវាកម្មប្រមូលសំរាមត្រូវធ្វើការពង្រីកឱ្យបានគ្រប់ទីកន្លែងទាំងអស់នៅទូទាំងទីប្រជុំជន ពិសេសនៅតំបន់លំនៅឋានអភិវឌ្ឍន៍ថ្មីប៉ែកខាងត្បូងទីប្រជុំជនជ្រៃធំ
- ពង្រីកទីតាំងចាក់ទុកដាក់សំរាមដែលមានស្រាប់ឱ្យបានធំជាងមុន និងរៀបចំគ្រប់គ្រងទៅតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ
- កំណត់តំបន់ចាក់ និងកែច្នៃសំរាម ដែលមានទីតាំង និងទំហំសមស្រប ខាងក្នុងឬក្រៅទីប្រជុំជន
- បង្កើនទីតាំងចាក់សំរាមបណ្តោះអាសន្ន និងការគ្រប់គ្រងសេវាកម្មប្រកបដោយប្រសិទ្ធភាព។

**៥.៣.៩- ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍**

- បំពាក់ម៉ាស៊ីនភ្លើង ឬស្ថានីយប្រើប្រេងម៉ាស៊ូត ដើម្បីកាត់បន្ថយការចំណាយ និងធានាសុវត្ថិភាព
- ពង្រីកបណ្តាញផ្គត់ផ្គង់អគ្គិសនី និងទូរគមនាគមន៍ ឱ្យបានសមស្រប

- ដំឡើង និងជួសជុលបណ្ដាញអគ្គិសនីបំភ្លឺតាមដងវិថី ឱ្យបានគ្រប់គ្រាន់តាមតម្រូវការជាក់ស្ដែង
- ធ្វើផែនការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់តំបន់ដែលពុំទាន់មានការប្រើប្រាស់ និងតំបន់បង្កើតថ្មី
- កសាងសមត្ថភាពអគ្គិសនីកម្ពុជា និងលើកទឹកចិត្តការវិនិយោគពីក្រុមហ៊ុនឯកជន
- ពិនិត្យឡើងវិញនូវអត្រាតម្លៃអគ្គិសនី ដើម្បីជួយសម្រួលដល់ជីវភាពប្រជាពលរដ្ឋ និងការទាក់ទាញអ្នកវិនិយោគទុនក្នុងការអភិវឌ្ឍនៅក្នុងតំបន់
- ពិនិត្យ ឬបង្កើតច្បាប់ បទបញ្ជា អំពីការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន
- ដំឡើង និងជួសជុលបណ្ដាញអគ្គិសនីបំភ្លឺនៅតាមផ្លូវជាតិលេខ២១ និងកំណាត់ផ្លូវជាតិលេខ ២១ ថ្មី និងនៅតាមផ្លូវក្នុងតំបន់រស់នៅមួយចំនួនទៀត
- ផ្សព្វផ្សាយ និងអប់រំមហាជនក្នុងការប្រើប្រាស់ថាមពលអគ្គិសនីដោយសន្សំសំចៃខ្ពស់។

### ៥.៤-ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង

ផែនការសកម្មភាពចែកចេញជា ៣ ដំណាក់កាល គឺការអនុវត្តរយៈពេលខ្លី មធ្យម និងវែង ដូចខាងក្រោម÷

#### ៥.៤.១-ការអនុវត្តរយៈពេលខ្លី

- ផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ដល់អន្តរវិស័យ វិនិយោគិន និងប្រជាពលរដ្ឋ
- ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលធនធានមនុស្ស និងមន្ត្រីជំនាញ អំពីផែនការ និងការអនុវត្តប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ
- រៀបចំគម្រោងអាទិភាព ពិសេសផែនការហេដ្ឋារចនាសម្ព័ន្ធ និងកែលម្អសោភ័ណភាពទីប្រជុំជន
- រៀបចំបទប្បញ្ញត្តិក្នុងការគ្រប់គ្រង និងអនុវត្តប្លង់គោលទីប្រជុំជនជ្រៃធំឱ្យមានប្រសិទ្ធភាព
- កែលម្អ និងពង្រីកផ្លូវជាតិលេខ២១ ពីស្ពាន៧៥ ឆ្ពោះទៅកាន់ព្រំប្រទល់វៀតណាម
- រៀបចំគម្រោងស្នើសុំសាងសង់ជើងទេរការពារច្រាំងបាក់តាមដងព្រែកជ្រៃធំ និងទន្លេបាសាក់
- រៀបចំគម្រោងស្នើសុំបង្កើតក្រុមការងារវាស់វែងចុះបញ្ជីជាប្រព័ន្ធនៅក្នុងតំបន់ទីប្រជុំជនជ្រៃធំ នៃភូមិព្រែកស្បូវ ភូមិព្រែកស៊ីង និងភូមិជ្រៃធំ
- រៀបចំទីតាំងចាក់ទុកដាក់ ឬកែច្នៃសំរាម និងធ្វើចលនាអនាម័យនិងបោសសម្អាតសំរាមនៅទីសាធារណៈ
- កំណត់តំបន់ និងទីតាំងសំខាន់ៗ តាមគម្រោងអាទិភាពនៃប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ
- រៀបចំផែនទីគ្រប់គ្រងក្នុងការដាក់ឈ្មោះផ្លូវ ឬលេខផ្លូវ និងទំហំផ្លូវបច្ចុប្បន្ន និងអនាគត
- តំបន់ច្រកទ្វារត្រួតពិនិត្យអន្តរជាតិផ្លូវគោក មានផ្ទៃដីប្រមាណ៣,៨៧ ហិកតា ស្ថិតនៅភូមិជ្រៃធំ
- ទីតាំងចាក់សំរាមបណ្ដោះអាសន្នមានផ្ទៃដីប្រមាណ១ ហិកតា ដែលមាននិយាមកាចំណុចកណ្ដាល (X=505548,Y=1210510)

- ទីតាំងទុកដាក់ និងប្រមូលសំរាមមានចំនួន ៧ ទីតាំងដូចជា÷
    - ទីតាំងទី១. ស្ថិតនៅភូមិព្រែកស៊ីង មានចម្ងាយ២៦ ម៉ែត្រ ពីផ្លូវជាតិលេខ២១ និងមាននិយាមកាចំណុចកណ្តាល (X=506824,Y=1212176)
    - ទីតាំងទី២. ស្ថិតនៅភូមិព្រែកស៊ីង មានចម្ងាយ១ ០០៨ ម៉ែត្រ ផ្លូវជាតិលេខ២១ និងមាននិយាមកាចំណុចកណ្តាល (X=506326,Y=1211548)
    - ទីតាំងទី៣. ស្ថិតនៅភូមិជ្រៃធំ ជាប់ផ្លូវជាតិលេខ២១ ថ្មី មានចម្ងាយ៣៨៨ ម៉ែត្រ និងមាននិយាមកាចំណុចកណ្តាល (X=507673,Y=1211618)
    - ទីតាំងទី៤. ស្ថិតនៅភូមិជ្រៃធំ ស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេស មានចម្ងាយ៥៦៩ ម៉ែត្រ និងមាននិយាមកាចំណុចកណ្តាល (X=508152,Y=1210640)
    - ទីតាំងទី៥. ស្ថិតនៅភូមិជ្រៃធំ មានចម្ងាយ ១ ០៥១ ម៉ែត្រ ពីកំណាត់ផ្លូវជាតិលេខ២១ ថ្មី និងមាននិយាមកាចំណុចកណ្តាល (X=508390,Y=1211155)
    - ទីតាំងទី៦. ស្ថិតនៅភូមិជ្រៃធំ ក្នុងតំបន់ពាណិជ្ជកម្ម និងមាននិយាមកាចំណុចកណ្តាល (X=506461,Y=1210253)
    - ទីតាំងទី៧. ស្ថិតនៅភូមិព្រែកស្បូវ ក្នុងតំបន់សេដ្ឋកិច្ចពិសេស និងមាននិយាមកាចំណុចកណ្តាល (X=504917,Y=1207077)។
- ស្ថានីយបូមទឹកមានចំនួន ៥ ទីតាំងដូចជា÷
    - ទីតាំងទី១. ស្ថិតនៅភូមិព្រែកស៊ីង មានចម្ងាយ៣០ ម៉ែត្រ ពីផ្លូវជាតិលេខ២១ និងមាននិយាមកាចំណុចកណ្តាល (X=506640,Y=1212399)
    - ទីតាំងទី២. ស្ថិតនៅភូមិជ្រៃធំ មានចម្ងាយ ៩០០ ម៉ែត្រ ពីកំណាត់ផ្លូវលេខ២១ ថ្មី និងមាននិយាមកាចំណុចកណ្តាល (X=508166,X=1211370)
    - ទីតាំងទី៣. ស្ថិតនៅភូមិព្រែកស្បូវ ក្នុងតំបន់លំនៅឋាន និងមាននិយាមកាចំណុចកណ្តាល (X=503673,Y=1205550)
    - ទីតាំងទី៤. ស្ថិតនៅភូមិព្រែកស្បូវ ក្នុងតំបន់កសិកម្ម និងមាននិយាមកាចំណុចកណ្តាល (X=504810,Y=1209085)
    - ទីតាំងទី៥. ស្ថិតនៅភូមិព្រែកស្បូវ ក្នុងតំបន់លំនៅឋាន និងមាននិយាមកាចំណុចកណ្តាល (X=503673,Y=1205550)
    - ទីតាំងទី៦. ស្ថិតនៅភូមិជ្រៃធំ ក្នុងតំបន់លំនៅឋាន និងមាននិយាមកាចំណុចកណ្តាល (X=505299,Y=1210260)។

## ៥.៤.២-ការអនុវត្តរយៈពេលមធ្យម

- បណ្តុះបណ្តាលធនធានមនុស្ស និងកសាងសមត្ថភាពគ្រប់គ្រងផែនការអភិវឌ្ឍន៍ទីប្រជុំជន
- រៀបចំផែនទីលម្អិតទៅតាមតំបន់នីមួយៗ និងផែនការហេដ្ឋារចនាសម្ព័ន្ធសាធារណៈទីប្រជុំជន
- រៀបចំការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៃភូមិទាំងបី គឺភូមិជ្រៃធំ ភូមិព្រៃកស្បវ និងភូមិព្រែកស៊ឹង
- កសាងសំណង់ច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិជ្រៃធំ- ឡុងប៊ិន និងរៀបចំប្រព័ន្ធគ្រប់គ្រង
- រៀបចំឈូសឆាយ ស្តារ និងសាងសង់ផ្លូវទាំងឡាយទៅតាមប្លង់គោលដែលបានអនុម័ត
- អប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីគោលការណ៍គ្រប់គ្រងសំណល់រឹង និងរាវ
- កសាងស្ពាន និងផ្លូវអ៊ុតកៅស៊ូ ពីចំណុចស្ពាន៧៥ ស្ពាន៧៦ ស្ពាន៧៧ រហូតដល់ព្រែកជ្រៃធំ
- បន្តជំរុញការបោះបង្គោលព្រំដែនផ្លូវការជាមួយភាគីវៀតណាម ឱ្យមានភាពច្បាស់លាស់
- តំបន់ច្រកទ្វារត្រួតពិនិត្យអន្តរជាតិផ្លូវទឹក មានផ្ទៃដីប្រមាណ៣,៨៦ ហិកតា ស្ថិតនៅភូមិជ្រៃធំ
- ចំណតមានផ្ទៃដីប្រមាណ១៥,៥១ ហិកតា ដែលមានចំនួន៤ ទីតាំងដូចជា÷
  - ទីតាំងទី១. ស្ថិតនៅភូមិជ្រៃធំ មានផ្ទៃដីប្រមាណ៣,៨៤ ហិកតា និយាមកាចំណុចកណ្តាល (X=508343,Y=1210130)
  - ទីតាំងទី២. ស្ថិតនៅភូមិព្រែកស៊ឹង មានផ្ទៃដីប្រមាណ៤,៥៨ ហិកតា និយាមកាចំណុចកណ្តាល (X=506603,Y=1210960)
  - ទីតាំងទី៣. ស្ថិតនៅភូមិជ្រៃធំ មានផ្ទៃដីប្រមាណ២,៨៧ ហិកតា និយាមកាចំណុចកណ្តាល (X=507623,Y=1211710)
  - ទីតាំងទី៤. ស្ថិតនៅភូមិជ្រៃធំ មានផ្ទៃដីប្រមាណ២,០៤ ហិកតា ក្នុងនោះមានទីតាំងចំណតដែលមាននិយាមកាចំណុចកណ្តាល (X=507624,Y=1210820)។
- ផែស្ងួតមានផ្ទៃដីប្រមាណ៦,៩៨ ហិកតា ស្ថិតនៅភូមិជ្រៃធំ និងមាននិយាមកាចំណុចកណ្តាល (X=506460,Y=1211650)
- អាងប្រព្រឹត្តកម្មមានចំនួន ៣ ទីតាំងដូចជា÷
  - ទីតាំងទី១. មានផ្ទៃដីប្រមាណ១៤,៥ ហិកតា ស្ថិតនៅភូមិព្រៃកស្បវ និងមាននិយាមកាចំណុចកណ្តាល (X=505169,Y=1209240)
  - ទីតាំងទី២. ស្ថិតនៅភូមិជ្រៃធំ ក្នុងតំបន់ពាណិជ្ជកម្ម និងមាននិយាមកាចំណុចកណ្តាល (X=506402,Y=1210030)
  - ទីតាំងទី៣. ស្ថិតនៅភូមិជ្រៃធំ និងមាននិយាមកាចំណុចកណ្តាល (X=505172,Y=1207230)
- កែលម្អ និងថែទាំបណ្តាញផ្លូវឱ្យមានដើមផ្កា និងដើមឈើអមសងខាងផ្លូវ និងសួនពុះចែកទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន បរិក្ខារផ្លូវថ្នល់ ដែលមានបរិស្ថានធម្មជាតិស្រស់បំព្រង និងបង្គោលភ្លើងភ្លឺចម្រុះពណ៌

- អប់រំ និងផ្សព្វផ្សាយដល់ប្រជាជនអំពីគោលការណ៍គ្រប់គ្រងសំណល់រឹង តាមរយៈការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ
- ពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលលូសាធារណៈ
- ណែនាំម្ចាស់សំណង់លំនៅឋាន សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈ ឱ្យរៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។

**៥.៤.៣-ការអនុវត្តរយៈពេលវែង**

- លើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយពន្លឺថាមពលព្រះអាទិត្យ និងប្រើប្រាស់រថយន្តដើរដោយអាគុយ
- ចំពោះសំណង់បណ្តោះអាសន្នតាមដងទន្លេបាសាក់ ព្រែក និងការតាំងទីលំនៅមិនរៀបរយមួយចំនួនទៀត ត្រូវបន្តដោះស្រាយតាមសារាចរលេខ០៣ ស.រ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ក្រុង និងទីប្រជុំជន
- រៀបចំបទប្បញ្ញត្តិ និងចាត់វិធានការគ្រប់គ្រងប្រភពផ្គត់ផ្គង់ទឹកប្រកបដោយប្រសិទ្ធភាព
- ចំពោះគម្រោងពង្រីកទីប្រជុំជន ចាំបាច់ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធសមស្របជាមុន ដូចជា÷ បណ្តាញផ្លូវ និងប្រព័ន្ធលូបង្ហូរទឹកកខ្វក់និងទឹកភ្លៀង ប្លង់បែងចែកតំបន់ប្រើប្រាស់ដីផ្សេងៗ ស្របតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង ដូចជា តំបន់រដ្ឋបាល តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់សេវាកម្ម តំបន់អភិរក្ស លម្ហសាធារណៈ និងតំបន់បម្រុងទុកសម្រាប់ជាប្រយោជន៍សាធារណៈ និងការអភិវឌ្ឍអនាគត។ល។ ដើម្បីគ្រប់គ្រងការសាងសង់សំណង់គ្រប់ប្រភេទក្នុងតំបន់ទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងគោលការណ៍អភិវឌ្ឍបៃតង សំដៅធ្វើឱ្យទីប្រជុំជនក្លាយជាទីកន្លែងរស់នៅល្អ ប្រកបដោយសុខុមាលភាព គុណភាព វឌ្ឍនភាព និងចីរភាព
- សាងសង់អាងប្រព្រឹត្តកម្មចំនួន៣ ទីតាំងស្ថិតនៅភូមិព្រែកស៊ីង១ កន្លែង និងភូមិព្រែកស្បូវ ២ កន្លែង
- ពង្រីកវិសាលភាពទីប្រជុំជន ទៅទិសខាងជើង ខាងកើត និងខាងលិចជាប់ខេត្តតាកែវ
- កសាងផ្លូវ និងស្ពានបន្ថែមសម្រាប់តភ្ជាប់ និងសម្រួលការអភិវឌ្ឍជាមួយខេត្តតាកែវ និងប្រទេសវៀតណាម។

## ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ មានជាអាទិ៍÷

- ថវិកាជាតិ
- ថវិកាវិនិយោគរវាងរដ្ឋ និងឯកជន
- ថវិកាដៃគូអភិវឌ្ឍន៍
- ថវិកាការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

### ៧.១- យន្តការ

យន្តការថ្នាក់ជាតិ មានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងស្ថាប័នតាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តមានរដ្ឋបាលខេត្តកណ្តាល គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្តាល គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកកោះធំ មន្ទីរនិងអង្គភាពជុំវិញខេត្ត អាជ្ញាធរមានសមត្ថកិច្ច។

យន្តការ ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ មានក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋបាលខេត្តកណ្តាល និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តកណ្តាល។

### ៧.២- ច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្ត

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្ត មានជាអាទិ៍៖ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គោលនយោបាយជាតិស្តីពីលំនៅឋាន អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ប្រកាសស្តីពីការអភិវឌ្ឍដី។

### ៧.៣- ភារកិច្ច នីតិវិធី និងគោលការណ៍

រដ្ឋបាលខេត្តកណ្តាល ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល ជាសេនាធិការ មានភារកិច្ច÷

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិត សម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីនេះ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គការ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើ ត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗ សម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃ ព្រមទាំងត្រូវមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ ឆ្នាំ ផែនការវិនិយោគ៣ ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់
- ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃនេះ ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ក្នុងរយៈពេល៥ ឆ្នាំម្តង ស្របតាមគោលការណ៍និងនីតិវិធីដែលបានកំណត់ ឬតាមពេលវេលា និងតម្រូវការចាំបាច់ជាក់ស្តែង សំដៅបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍សង្គមជាតិ
- រដ្ឋបាលខេត្តកណ្ដាល ដែលមានរដ្ឋបាលស្រុកកោះធំជាចំណុះ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តជាសេនាធិការ ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំជូនក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្ដាល។

គោលការណ៍នៃការត្រួតពិនិត្យ និងវាយតម្លៃត្រូវផ្អែកលើសូចនាករនៃផលប៉ះពាល់សង្គម និងបរិស្ថាន ដែលជាកត្តាគូសបញ្ជាក់អំពីប្រសិទ្ធភាពនៃប្លង់គោលប្រើប្រាស់ដី ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ប្រកបដោយចីរភាព។

## ៨-សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ តាមរយៈការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំត្រូវបានរៀបចំឡើង និងសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គឺជាឧបករណ៍គតិយុត្តគោលសម្រាប់ការអនុវត្ត និងសម្របសម្រួលស្ថាប័នពាក់ព័ន្ធតាមវិស័យនានា ដើម្បីសម្រេចបានចក្ខុវិស័យដល់ឆ្នាំ២០៣០ គឺ **“ជ្រៃធំ ជាទីប្រជុំជនព្រំដែនមិត្តភាព សន្តិភាព សហប្រតិបត្តិការ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចពាណិជ្ជកម្ម និងសេវាកម្ម ប្រកបដោយចីរភាព”** តាមរយៈការរៀបចំ និងបង្កើតទៅជា៖ ១). តំបន់ពាណិជ្ជកម្ម សេវាកម្ម និងដឹកជញ្ជូនប្រកបដោយភាពលេចធ្លោ និងប្រសិទ្ធភាពខ្ពស់ ២). តំបន់ទេសចរណ៍ និងលម្ហែកម្សាន្តប្រកបដោយភាពទាក់ទាញ និងការពេញនិយម ៣). តំបន់ដែលមានសន្តិភាព និងសហប្រតិបត្តិការអន្តរជាតិ

ប្រកបដោយភាតរភាព ៤). តំបន់ដែលមានហេដ្ឋារចនាសម្ព័ន្ធ និងអភិបាលកិច្ចល្អ ដើម្បីឆ្លើយតបបានតាមតម្រូវការរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍដីធ្លីប្រកបដោយចីរភាពនៅតាមព្រំដែន ៥). តំបន់ទីប្រជុំជនប្រកបដោយសុខដុមនីយកម្មនៃការរស់នៅ និងប្រកបការងារ សំដៅរៀបចំឱ្យក្លាយទៅជាទីប្រជុំជនទំនើបនាពេលអនាគត។

គោលដៅអភិវឌ្ឍន៍ទាំងនេះ នឹងរួមចំណែកធ្វើឱ្យមានការផ្លាស់ប្ដូរ និងប្រែក្លាយសេដ្ឋកិច្ចកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជន ផ្នែកធុរកិច្ច និងសង្គមស៊ីវិល ក្នុងការចូលរួមចំណែកអនុវត្ត តាមដាន និងវាយតម្លៃចំពោះប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ គណៈកម្មាធិការរៀបចំដែនដីនិងនគរូប-នីយកម្មខេត្តកណ្ដាល គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មស្រុកកោះធំ និងអាជ្ញាធរមានសមត្ថកិច្ចត្រូវជំរុញការផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងត្រូវរាយការណ៍ពីលទ្ធផលនៃការអនុវត្តជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

## ៩-អនុសាសន៍

ដើម្បីឱ្យដំណើការកសាង និងអនុវត្តប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំទទួលបានជោគជ័យ ចាំបាច់ពិនិត្យនូវសំណូមពរ និងអនុសាសន៍មួយចំនួនដូចខាងក្រោម÷

ទី១). តាមរយៈតំបន់ប្រើប្រាស់ដីនីមួយៗត្រូវរៀបចំផែនការប្រើប្រាស់ដីលម្អិត ចុះបញ្ជីដីធ្លីឱ្យបានច្បាស់លាស់ និងរៀបចំបទប្បញ្ញត្តិនានាក្នុងការគ្រប់គ្រងប្រើប្រាស់ និងសំណង់ឱ្យមានប្រសិទ្ធភាព។

ទី២). រៀបចំឯកសារ និងកម្មវិធី ឬសកម្មភាពទាក់ទាញទាំងឡាយ ដើម្បីធ្វើការផ្សព្វផ្សាយជាទូទៅ ឬអំពាវនាវតាមគោលដៅពិសេសៗ ដោយឈរលើគោលនយោបាយលើកទឹកចិត្ត និងទាក់ទាញអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេស ដើម្បីចូលមកវិនិយោគ។

ទី៣). ពិនិត្យវាយតម្លៃនិងកែលម្អប្លង់គោលប្រើប្រាស់ដីនេះរៀងរាល់៥ (ប្រាំ) ឆ្នាំម្ដង ដើម្បីឱ្យឆ្លើយតបទៅនឹងកាលៈទេសៈប្រែប្រួល និងតម្រូវការសេដ្ឋកិច្ចសង្គមជាក់ស្ដែង។

ទី៤). គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ជួយគាំទ្រដល់ខេត្តកណ្ដាល ក្នុងការអនុវត្តប្លង់គោលប្រើប្រាស់ដីនេះឱ្យមានប្រសិទ្ធភាព ដែលធានាបាននូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការកែលម្អបរិស្ថាន និងលើកកម្ពស់សោភ័ណភាព ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

## សទ្ទានុក្រម

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈវិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំងតំបន់ទទួលឥទ្ធិពល ក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភ័ណភាព សមធម៌ និងសមាហរណកម្ម។

**ផែនការរៀបចំដែនដីថ្នាក់ជាតិ តាមតំបន់ ថ្នាក់ខេត្ត** សំដៅដល់ផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្ត ដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រ និងតំបន់នីមួយៗ ក្នុងក្របខណ្ឌថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។

**ប្លង់គោលប្រើប្រាស់ដី ឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុប សម្រាប់ការអភិវឌ្ឍរូបវន្ត និងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុង ព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍និងអភិរក្សទីក្រុង ទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ញានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍដី និងរយៈពេលការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្តាញគមនាគមន៍ និងការធ្វើសមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍន៍ទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបបន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើនទីក្រុង ដែលរួមមានការបង្ហាញអំពីការរៀបចំការរចនាទម្រង់ រូបរាង និងសោភ័ណភាពនៃរចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជន ដោយប៉ាន់ប្រមាណពីសក្តានុពលដីនិងធនធានទឹក លទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

**ប្រភេទដីអាចសាងសង់បាន** សំដៅដល់ប្រភេទដីដែលជំរុញឱ្យមានការអភិវឌ្ឍ និងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លម្ហសាធារណៈ និងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ប្រភេទដីកម្រិតការសាងសង់** សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍ គិតជាភាគរយ។

**សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

**តំបន់ស្នូលនៃការអភិវឌ្ឍ** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់ ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់ សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។

**អ័ក្សនៃការអភិវឌ្ឍ** សំដៅដល់បណ្តាញផ្លូវគមនាគមន៍ ឬច្រករបៀងតភ្ជាប់ពីតំបន់អភិវឌ្ឍន៍មួយទៅតំបន់អភិវឌ្ឍន៍មួយទៀត ដែលអាចឱ្យតំបន់ជាប់ជិតខាងតាមអ័ក្សទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមអ័ក្សនេះបាន។

**តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។

**បណ្តាញបៃតង** សំដៅដល់សួនសាធារណៈ និងដើមឈើដែលរៀបចំប្រទាក់ក្រឡាគ្នាតាមចិញ្ចើមផ្លូវភ្ជាប់ទៅសួនទីក្រុង។

**ការត្រួតពិនិត្យការអភិវឌ្ឍ** សំដៅដល់ការត្រួតពិនិត្យការអនុវត្តស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**អាងទន្លេ** សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។

**ទឹកក្រោមដី** សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

**ទន្លេ** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និង ពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។

**ស្ទឹង** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរង ទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ និងសមុទ្រ។

**ព្រែក** សំដៅដល់ផ្លូវទឹកធម្មជាតិ ឬសិប្បនិម្មិតដែលនាំទឹកចេញឬចូលពីទន្លេ ឬស្ទឹង និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**អូរ** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះ និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេ ឬបឹង។

**ជ្រោះ** សំដៅដល់ជ្រលង ឬល្បាក់ទឹកធម្មជាតិដែលកើតឡើងដោយសារបាតុភូតធម្មជាតិនៃការហូរច្រោះ ដោយសារចរន្តទឹកពីតំបន់ភ្នំ ឬតំបន់ខ្ពង់រាប។

**បឹងបួ** សំដៅដល់ល្ហាលទឹកធំល្វឹងល្វើយកើតពីទីជម្រាល ឬជម្រៅធម្មជាតិដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាល និងមានប្រភពមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង។

**អាងទឹក** សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិ ឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។

**ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមលូ ឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួមមានតាមលក្ខណៈបច្ចេកវិជ្ជា ឬលក្ខណៈធម្មជាតិ។

**ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម** សំដៅដល់រោងចក្រកសម្អាតទឹកកខ្វក់រួមរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទីប្រជុំជន។

**ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួច មានដូចជាទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅឋាន បុរីលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់ទីរមណីយដ្ឋាន ឬមជ្ឈមណ្ឌលកំសាន្ត។

**សំណល់រាវ** សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

**ប្រព័ន្ធលូ** សំដៅដល់បណ្តាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមាន÷ តំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ (បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)។

**អាងបង្គន់អនាម័យ** សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យ និងបន្ទប់ទឹក ដើម្បីស្តុក និងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។

**សំពៅជ្រៃ** ជាឈ្មោះតំបន់សម្រាប់អភិវឌ្ឍន៍រមណីយដ្ឋានធម្មជាតិ ដែលជាអត្តសញ្ញាណភូមិសាស្ត្រនៃឃុំសំពៅពូន ជាមួយនឹងទីប្រជុំជនជ្រៃធំ ស្រុកកោះធំ ខេត្តកណ្តាល។

## ឯកសារឧបសម្ព័ន្ធ

- របាយការណ៍បច្ចេកទេសលម្អិតប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ
- ផែនទីប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ចក្ខុវិស័យ ឆ្នាំ២០៣០
- ផែនទីប្លង់គោលប្រើប្រាស់ដីលម្អិតទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ចក្ខុវិស័យ ឆ្នាំ២០៣០
- ផែនទីបណ្តាញផ្លូវទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ចក្ខុវិស័យ ឆ្នាំ២០៣០
- ផែនទីតំបន់អាចសាងសង់បាន និងកម្រិតការសាងសង់ទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ចក្ខុវិស័យឆ្នាំ២០៣០
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងលម្ហបៃតងទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ចក្ខុវិស័យឆ្នាំ២០៣០៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីលម្អិតទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ចក្ខុវិស័យឆ្នាំ២០៣០

## Detail Land Use Planning of Chrey Thum Urban Area, 2030



គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្តាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកោះធំ

# ផែនទីបណ្តាញផ្លូវទីប្រជុំជនព្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ចក្ខុវិស័យឆ្នាំ២០៣០

## Road Master Plan of Chrey Thum Urban Area, 2030

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ




### ផែនទីតំបន់ឥណ្ឌូចិន



ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្តោយពី ១០២° ដល់ ១០៨° និងរយៈទទឹងពី ១០° ដល់ ១៥°។

### ផែនទីព្រះរាជាណាចក្រកម្ពុជា



ដោយមានផ្ទៃដី ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា ដែលក្នុងនោះមានបណ្តោយ ៥៦០ គីឡូម៉ែត្រ និងទទឹង ៤៤០ គីឡូម៉ែត្រ។ មានព្រំប្រទល់ដីគោកជាប់នឹងប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម ប្រវែង ២ ១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០ គីឡូម៉ែត្រ។

### ផែនទីតំបន់ទីប្រជុំជនព្រៃធំ ឃុំសំពៅពូន



ឃុំសំពៅពូនមានទីតាំងស្ថិតនៅត្រើយខាងលិចទន្លេបាសាក់មានចម្ងាយ ៧៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ឃុំនេះមានផ្ទៃក្រឡា ទំហំ ៦៧.០១ គីឡូម៉ែត្រក្រឡា និងមាននិយាមការលើរយៈបណ្តោយពី ១០៥°២'០" ដល់ ១០៥°៥'០" និងមានរយៈទទឹង ១០°៥៨'០" ដល់ ១០°៥៤'០" ដែលមាន ព្រំប្រទល់ខាងជើងឈាងខាងកើតជាប់ឃុំឈើខ្មៅ ខាងត្បូងនិងខាងកើត ជាប់ប្រទេសវៀតណាម និងខាងលិចជាប់ខេត្តតាកែវ។




ទីប្រជុំជនព្រៃធំ ស្ថិតនៅក្នុងស្រុកកោះធំ ភាគខាងត្បូងនៃប្រទេសកម្ពុជា ដែលមាន ចម្ងាយ ៧៥ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានចម្ងាយ ៦៤ គីឡូម៉ែត្រ ពីទីរួម ខេត្តកណ្តាល តាមបណ្តោយផ្លូវជាតិលេខ២១អា។ ទីប្រជុំជននេះមានផ្ទៃដី ប្រមាណ ២១.៥៨ គីឡូម៉ែត្រក្រឡា និងមានប្រព័ន្ធនិយាមការរយៈបណ្តោយពី ១០៥°២'០" ដល់ ១០៥°៥'០" និងមានរយៈទទឹង ១០°៥៨'០" ដល់ ១០°៥៤'០" ដែលមានភូមិចំនួន ០៣ រួមមាន: ភូមិព្រែកស៊ីង ភូមិព្រៃធំ និងភូមិព្រែកស្បូវ។

### ការពិពណ៌នា

**ការពិពណ៌នា:**

- ផែនទីនេះបង្ហាញពីការប្រើប្រាស់ដី រួមជាមួយបណ្តាញហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញធារាសាស្រ្តក្នុងទីប្រជុំជនព្រៃធំ
- ផែនទីនេះផលិតឡើងដោយ ក្រុមការងារសម្របសម្រួល និងគាំទ្របច្ចេកទេសរបស់នាយកដ្ឋាននគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មាត្រដ្ឋានផែនទីនេះសម្រាប់បោះពុម្ពលើក្រដាសA3

**ប្រភពទិន្នន័យ:**

- ការរៀបចំផែនទីនេះ ត្រូវបានគូសដោយប្រើរូបថតពីលើអាកាស និងដោយរួមបញ្ចូលនូវការអង្កេតដោយផ្ទាល់ និងប្រើប្រាស់ឧបករណ៍GPS Handle
- ផែនទីនេះរៀបចំឡើងដោយនាយកដ្ឋាននគរូបនីយកម្ម ក្រោមការសម្របសម្រួលពីមន្ទីរ ដនសស ខេត្តកណ្តាល និងការិយាល័យ ដនសក ស្រុកកោះធំ រួមជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងការិយាល័យជំនាញពាក់ព័ន្ធ។

**ព្រំប្រទល់: ប្រទេស ខេត្ត ស្រុក និងឃុំ**

- ព្រំប្រទល់ប្រទេស ខេត្ត ស្រុក ឃុំ: ទិន្នន័យ JICA 2002 គូសពឹងផ្អែកលើរូបភាពSPOT 1998-2002
- ព្រំប្រទល់ស្រុក ឃុំ ទីប្រជុំជន មានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន

មាត្រដ្ឋាន ១ : ៥០ ០០០

0 0.175 0.35 0.7 1.05 1.4 គីឡូម៉ែត្រ

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្តាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកោះធំ

គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្ដាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកោះធំ

# ផែនទីតំបន់អាចសាងសង់បាន និងកម្រិតការសាងសង់ ទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ចក្ខុវិស័យឆ្នាំ២០៣០

## Building Area and Control Area Map in Chrey Thum Urban, 2030

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ




### ផែនទីតំបន់ឥណ្ឌូចិន



ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្ដោយពី ១០២° ដល់ ១០៨° និងរយៈទទឹងពី ១០° ដល់ ១៥°។

### ផែនទីព្រះរាជាណាចក្រកម្ពុជា




ដោយមានផ្ទៃដី ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា ដែលក្នុងនោះមានបណ្ដោយ ៥៦០ គីឡូម៉ែត្រ និងទទឹង ៤៤០ គីឡូម៉ែត្រ។ មានព្រំប្រទល់ដីគោកជាប់នឹងប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម ប្រវែង ២ ១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០ គីឡូម៉ែត្រ។

### ផែនទីតំបន់ទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន




ឃុំសំពៅពូនមានទីតាំងស្ថិតនៅត្រើយខាងលិចទន្លេបាសាក់មានចម្ងាយ ៧៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ឃុំនេះមានផ្ទៃក្រឡា ទំហំ ៦៧.០១ គីឡូម៉ែត្រក្រឡា និងមាននិយាមកាលើរយៈបណ្ដោយពី ១០៥°២'០" ដល់ ១០៥°៥'០" និងមានរយៈទទឹង ១០°៥៨'០" ដល់ ១០°៥៤'០" ដែលមាន ព្រំប្រទល់ខាងជើងឈាងខាងកើតជាប់ឃុំឈើខ្មៅ ខាងត្បូងនិងខាងកើត ជាប់ប្រទេសវៀតណាម និងខាងលិចជាប់ខេត្តតាកែវ។




ទីប្រជុំជនជ្រៃធំ ស្ថិតនៅក្នុងស្រុកកោះធំ ភាគខាងត្បូងនៃប្រទេសកម្ពុជា ដែលមាន ចម្ងាយ ៧៥ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានចម្ងាយ ៦៤ គីឡូម៉ែត្រ ពីទីរួម ខេត្តកណ្ដាល តាមបណ្ដោយផ្លូវជាតិលេខ២១អ។ ទីប្រជុំជននេះមានផ្ទៃដី ប្រមាណ ២១.៥៤ គីឡូម៉ែត្រក្រឡា និងមានប្រព័ន្ធនិយាមការរយៈបណ្ដោយពី ១០៥°២'០" ដល់ ១០៥°៥'០" និងមានរយៈទទឹង ១០°៥៨'០" ដល់ ១០°៥៤'០" ដែលមានភូមិចំនួន ០៣ រួមមានៈ ភូមិព្រែកស៊ីង ភូមិជ្រៃធំ និងភូមិព្រែកស្បូវ។

### ការពិពណ៌នា

**ការពិពណ៌នា:**

- ផែនទីនេះបង្ហាញពីការប្រើប្រាស់ដី រួមជាមួយបណ្ដាញហេដ្ឋារចនាសម្ព័ន្ធ និងបណ្ដាញធារាសាស្ត្រក្នុងទីប្រជុំជនជ្រៃធំ
- ផែនទីនេះផលិតឡើងដោយ ក្រុមការងារសម្របសម្រួល និងគាំទ្របច្ចេកទេសរបស់នាយកដ្ឋាននគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មាត្រដ្ឋានផែនទីនេះសម្រាប់បោះពុម្ពលើក្រដាស A3

**ប្រភពទិន្នន័យ:**

- ការរៀបចំផែនទីនេះ ត្រូវបានគូសដោយប្រើរូបថតពីលើអាកាស និងដោយរួមបញ្ចូលនូវការអង្កេតដោយផ្ទាល់ និងប្រើប្រាស់ឧបករណ៍GPS Handle
- ផែនទីនេះរៀបចំឡើងដោយនាយកដ្ឋាននគរូបនីយកម្ម ក្រោមការសម្របសម្រួលពីមន្ទីរ ដនសស ខេត្តកណ្ដាល និងការិយាល័យ ដនសក ស្រុកកោះធំ រួមជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងការិយាល័យជំនាញពាក់ព័ន្ធ។

**ព្រំប្រទល់: ប្រទេស ខេត្ត ស្រុក និងឃុំ**

- ព្រំប្រទល់ប្រទេស ខេត្ត ស្រុក ឃុំៈ ទិន្នន័យ JICA 2002 គូសពឹងផ្អែកលើរូបភាពSPOT 1998-2002
- ព្រំប្រទល់ស្រុក ឃុំ ទីប្រជុំជន មានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន

**មាត្រដ្ឋាន ១ : ៣៥ ០០០**

0 0.25 0.5 1 1.5 2 គីឡូម៉ែត្រ

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្ដាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកោះធំ
គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្ដាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកោះធំ

# ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ និងលំហបៃតង ទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ចក្ខុវិស័យឆ្នាំ២០៣០

## Tourism and Green Space Development Map in Chrey Thum Urban, 2030

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ




### ផែនទីតំបន់ឥណ្ឌូចិន



ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្ដោយពី ១០២° ដល់ ១០៨° និងរយៈទទឹងពី ១០° ដល់ ១៥°។

### ផែនទីព្រះរាជាណាចក្រកម្ពុជា




ដោយមានផ្ទៃដី ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា ដែលក្នុងនោះមានបណ្ដោយ ៥៦០ គីឡូម៉ែត្រ និងទទឹង ៤៤០ គីឡូម៉ែត្រ។ មានព្រំប្រទល់ដីគោកជាប់នឹង ប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម ប្រវែង ២ ១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០ គីឡូម៉ែត្រ។

### ផែនទីតំបន់ទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន




ឃុំសំពៅពូនមានទីតាំងស្ថិតនៅត្រើយខាងលិចទន្លេបាសាក់មានចម្ងាយ ៧៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ឃុំនេះមានផ្ទៃក្រឡា ទំហំ ៦៧.០១ គីឡូម៉ែត្រក្រឡា និងមាននិយាមការលើរយៈបណ្ដោយពី ១០៥°២'០" ដល់ ១០៥°៥'០" និងមានរយៈទទឹង ១០°៥៨'០" ដល់ ១០°៥៤'០" ដែលមាន ព្រំប្រទល់ខាងជើងឈាងខាងកើតជាប់ ឃុំឈើខ្មៅ ខាងត្បូងនិងខាងកើត ជាប់ប្រទេសវៀតណាម និងខាងលិចជាប់ខេត្តតាកែវ។




ទីប្រជុំជនជ្រៃធំ ស្ថិតនៅក្នុងស្រុកកោះធំ ភាគខាងត្បូងនៃប្រទេសកម្ពុជា ដែលមាន ចម្ងាយ ៧៥ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានចម្ងាយ ៦៤ គីឡូម៉ែត្រ ពីទីរួម ខេត្តកណ្ដាល តាមបណ្ដោយផ្លូវជាតិលេខ២១អា។ ទីប្រជុំជននេះមានផ្ទៃដី ប្រមាណ ២១.៥៤ គីឡូម៉ែត្រក្រឡា និងមានប្រព័ន្ធនិយាមការរយៈបណ្ដោយពី ១០៥°២'០" ដល់ ១០៥°៥'០" និងមានរយៈទទឹង ១០°៥៨'០" ដល់ ១០°៥៤'០" ដែលមានភូមិចំនួន ០៣ រួមមានៈ ភូមិព្រែកស៊ីង ភូមិជ្រៃធំ និងភូមិព្រែកស្បូវ។

### ការពិពណ៌នា

**ការពិពណ៌នា:**

- ផែនទីនេះបង្ហាញពីការប្រើប្រាស់ដី រួមជាមួយបណ្ដាញហេដ្ឋារចនាសម្ព័ន្ធ និងបណ្ដាញជាភាសាស្ត្រក្នុងទីប្រជុំជនជ្រៃធំ
- ផែនទីនេះផលិតឡើងដោយ ក្រុមការងារសម្របសម្រួល និងគាំទ្របច្ចេកទេសរបស់នាយកដ្ឋាននគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មាត្រដ្ឋានផែនទីនេះសម្រាប់បោះពុម្ពលើក្រដាស A3

**ប្រភពទិន្នន័យ:**

- ការរៀបចំផែនទីនេះ ត្រូវបានគូសដោយប្រើរូបថតពីលើអាកាស និងដោយរួមបញ្ចូលនូវការអង្កេតដោយផ្ទាល់ និងប្រើប្រាស់ឧបករណ៍GPS Handle
- ផែនទីនេះរៀបចំឡើងដោយនាយកដ្ឋាននគរូបនីយកម្ម ក្រោមការសម្របសម្រួលពីមន្ទីរ ដនសស ខេត្តកណ្ដាល និងការិយាល័យ ដនសក ស្រុកកោះធំ រួមជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងការិយាល័យជំនាញពាក់ព័ន្ធ។

**ព្រំប្រទល់: ប្រទេស ខេត្ត ស្រុក និងឃុំ**

- ព្រំប្រទល់ប្រទេស ខេត្ត ស្រុក ឃុំ: ទិន្នន័យ JICA 2002 គូសពឹងផ្អែកលើរូបភាព SPOT 1998-2002
- ព្រំប្រទល់ស្រុក ឃុំ ទីប្រជុំជន មានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន

ជ ខ ត ល

មាត្រដ្ឋាន ១ : ៣៥ ០០០

0 0.25 0.5 1 1.5 2 គីឡូម៉ែត្រ

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្ដាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកោះធំ

គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្តាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកោះធំ

# ផែនទីប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ចក្ខុវិស័យឆ្នាំ២០៣០

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ....០០៥ សសរ....ចុះថ្ងៃ....ខែ....ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី....២៤....ខែ....ធ្នូ....ឆ្នាំ ២០១៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**




### ផែនទីតំបន់ឥណ្ឌូចិន




ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្តោយពី ១០២° ដល់ ១០៨° និងរយៈទទឹងពី ១០° ដល់ ១៥°។

### ផែនទីព្រះរាជាណាចក្រកម្ពុជា




ដោយមានផ្ទៃដី ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា ដែលក្នុងនោះមានបណ្តោយ ៥៦០ គីឡូម៉ែត្រ និងទទឹង ៤៤០ គីឡូម៉ែត្រ។ មានព្រំប្រទល់ដីគោកជាប់នឹងប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម ប្រវែង ២ ១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០ គីឡូម៉ែត្រ។

### ផែនទីតំបន់ទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន




ឃុំសំពៅពូនមានទីតាំងស្ថិតនៅត្រើយខាងលិចទន្លេបាសាក់មានចម្ងាយ ៧៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ឃុំនេះមានផ្ទៃក្រឡា ទំហំ ៦៧.០១ គីឡូម៉ែត្រក្រឡា និងមាននិយាមការលើរយៈបណ្តោយពី ១០៥°២'០" ដល់ ១០៥°៥'០" និងមានរយៈទទឹង ១០°៥៨'០" ដល់ ១០°៥៤'០" ដែលមាន ព្រំប្រទល់ខាងជើងឈាងខាងកើតជាប់ឃុំឈើខ្មៅ ខាងត្បូងនិងខាងកើត ជាប់ប្រទេសវៀតណាម និងខាងលិចជាប់ខេត្តតាកែវ។




ទីប្រជុំជនជ្រៃធំ ស្ថិតនៅក្នុងស្រុកកោះធំ ភាគខាងត្បូងនៃប្រទេសកម្ពុជា ដែលមាន ចម្ងាយ ៧៥ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានចម្ងាយ ៦៤ គីឡូម៉ែត្រ ពីទីរួម ខេត្តកណ្តាល តាមបណ្តោយផ្លូវជាតិលេខ២១អា។ ទីប្រជុំជននេះមានផ្ទៃដី ប្រមាណ ២១.៥៤ គីឡូម៉ែត្រក្រឡា និងមានប្រព័ន្ធនិយាមការរយៈបណ្តោយពី ១០៥°២'០" ដល់ ១០៥°៥'០" និងមានរយៈទទឹង ១០°៥៨'០" ដល់ ១០°៥៤'០" ដែលមានភូមិចំនួន ០៣ រួមមាន: ភូមិព្រែកស៊ីង ភូមិជ្រៃធំ និងភូមិព្រែកស្បូវ។

## ការពិពណ៌នា

**ការពិពណ៌នា:**

- ផែនទីនេះបង្ហាញពីការប្រើប្រាស់ដី រួមជាមួយបណ្តាញហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញធារាសាស្ត្រក្នុងទីប្រជុំជនជ្រៃធំ
- ផែនទីនេះផលិតឡើងដោយ ក្រុមការងារសម្របសម្រួល និងគាំទ្របច្ចេកទេសរបស់នាយកដ្ឋាននគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មាត្រដ្ឋានផែនទីនេះសម្រាប់បោះពុម្ពលើក្រដាសA0

**ប្រភពទិន្នន័យ:**

- ការរៀបចំផែនទីនេះ ត្រូវបានគូសដោយប្រើរូបថតពីលើអាកាស និងដោយរួមបញ្ចូលនូវការអង្កេតដោយផ្ទាល់ និងប្រើប្រាស់ឧបករណ៍GPS Handle
- ផែនទីនេះរៀបចំឡើងដោយនាយកដ្ឋាននគរូបនីយកម្ម ក្រោមការសម្របសម្រួលពីមន្ទីរ ដនសស ខេត្តកណ្តាល និងការិយាល័យ ដនសក ស្រុកកោះធំ រួមជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងការិយាល័យជំនាញពាក់ព័ន្ធ។

**ព្រំប្រទល់: ប្រទេស ខេត្ត ស្រុក និងឃុំ**

- ព្រំប្រទល់ប្រទេស ខេត្ត ស្រុក ឃុំ: ទិន្នន័យ JICA 2002 គូសពឹងផ្អែកលើរូបភាពSPOT 1998-2002
- ព្រំប្រទល់ស្រុក ឃុំ ទីប្រជុំជន មានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន




សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្តាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកោះធំ
គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

លេខ:....០០៥ សសរ....
បានឃើញនិងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ....ខែ....ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី....២៤....ខែ....ធ្នូ....ឆ្នាំ២០១៨
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**
ជា សុផារ៉ា

លេខ:....
បានឃើញ និងពិនិត្យត្រឹមត្រូវ
គោរពជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ....ខែ....ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី....២១....ខែ....ធ្នូ....ឆ្នាំ២០១៨
**អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**
បណ្ឌិត បែន_សុផល

លេខ:....
បានឃើញនិងឯកភាព
គោរពជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។
ធ្វើនៅខេត្តកណ្តាល ថ្ងៃ....ខែ....ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី....១៣....ខែ....ធ្នូ....ឆ្នាំ២០១៨
**អភិបាលនៃគណៈអភិបាលខេត្ត និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្តាល**
ម៉ៅ ធនិន្នណា

លេខ:....
បានឃើញនិងឯកភាព
គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្តាល មេត្តាពិនិត្យ និងសម្រេច។
ធ្វើនៅស្រុកកោះធំ ថ្ងៃ....ខែ....ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី....០៥....ខែ....ធ្នូ....ឆ្នាំ២០១៨
**អភិបាលនៃគណៈអភិបាលស្រុក និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ស្រុកកោះធំ**
អេង_មោក្ខ

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្ដាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកោះធំ

# ផែនទីប្លង់គោលប្រើប្រាស់ដីទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ចក្ខុវិស័យឆ្នាំ២០៣០

ឧបសម្ព័ន្ធនៃសេចក្ដីសម្រេចលេខ......០០៥......ចុះថ្ងៃ..................ខែ..................ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី......ខែ......ឆ្នាំ ២០១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ




### ផែនទីតំបន់ឥណ្ឌូចិន




ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្ដោយពី ១០២° ដល់ ១០៨° និងរយៈទទឹងពី ១០° ដល់ ១៥°។

ដោយមានផ្ទៃដី ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា ដែលក្នុងនោះមានបណ្ដោយ ៥៦០ គីឡូម៉ែត្រ និងទទឹង ៤៤០ គីឡូម៉ែត្រ។ មានព្រំប្រទល់ដីគោកជាប់នឹងប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម ប្រវែង ២ ១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០ គីឡូម៉ែត្រ។

### ផែនទីព្រះរាជាណាចក្រកម្ពុជា




### ផែនទីតំបន់ទីប្រជុំជនជ្រៃធំ ឃុំសំពៅពូន




ឃុំសំពៅពូនមានទីតាំងស្ថិតនៅត្រើយខាងលិចទន្លេបាសាក់មានចម្ងាយ ៧៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ឃុំនេះមានផ្ទៃក្រឡា ទំហំ ៦៧.០១ គីឡូម៉ែត្រក្រឡា និងមាននិយាមកាលើរយៈបណ្ដោយពី ១០៥°២'០" ដល់ ១០៥°៥'០" និងមានរយៈទទឹង ១០°៥៨'០" ដល់ ១០°៥៤'០" ដែលមាន ព្រំប្រទល់ខាងជើងឈាងខាងកើតជាប់ឃុំឈើខ្មៅ ខាងត្បូងនិងខាងកើត ជាប់ប្រទេសវៀតណាម និងខាងលិចជាប់ខេត្តតាកែវ។




ទីប្រជុំជនជ្រៃធំ ស្ថិតនៅក្នុងស្រុកកោះធំ ភាគខាងត្បូងនៃប្រទេសកម្ពុជា ដែលមាន ចម្ងាយ ៧៥ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានចម្ងាយ ៦៤ គីឡូម៉ែត្រ ពីទីរួម ខេត្តកណ្ដាល តាមបណ្ដោយផ្លូវជាតិលេខ២១អា។ ទីប្រជុំជននេះមានផ្ទៃដី ប្រមាណ ២១.៥៤ គីឡូម៉ែត្រក្រឡា និងមានប្រព័ន្ធនិយាមការយៈបណ្ដោយពី ១០៥°២'០" ដល់ ១០៥°៥'០" និងមានរយៈទទឹង ១០°៥៨'០" ដល់ ១០°៥៤'០" ដែលមានភូមិចំនួន ០៣ រួមមាន: ភូមិព្រែកស៊ីង ភូមិជ្រៃធំ និងភូមិព្រែកស្បូវ។

### ការពិពណ៌នា

**ការពិពណ៌នា:**

- ផែនទីនេះបង្ហាញពីការប្រើប្រាស់ដី រួមជាមួយបណ្ដាញហេដ្ឋារចនាសម្ព័ន្ធ និងបណ្ដាញធារាសាស្ត្រក្នុងទីប្រជុំជនជ្រៃធំ
- ផែនទីនេះផលិតឡើងដោយ ក្រុមការងារសម្របសម្រួល និងគាំទ្របច្ចេកទេសរបស់នាយកដ្ឋាននគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មាត្រដ្ឋានផែនទីនេះសម្រាប់បោះពុម្ពលើក្រដាស A0

**ប្រភពទិន្នន័យ:**

- ការរៀបចំផែនទីនេះ ត្រូវបានគូសដោយប្រើរូបថតពីលើអាកាស និងដោយរួមបញ្ចូលនូវការអង្កេតដោយផ្ទាល់ និងប្រើប្រាស់ឧបករណ៍GPS Handle
- ផែនទីនេះរៀបចំឡើងដោយនាយកដ្ឋាននគរូបនីយកម្ម ក្រោមការសម្របសម្រួលពីមន្ទីរ ដនសស ខេត្តកណ្ដាល និងការិយាល័យ ដនសភ ស្រុកកោះធំ រួមជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងការិយាល័យជំនាញពាក់ព័ន្ធ។

**ព្រំប្រទល់: ប្រទេស ខេត្ត ស្រុក និងឃុំ**

- ព្រំប្រទល់ប្រទេស ខេត្ត ស្រុក ឃុំ: ទិន្នន័យ JICA 2002 គូសពឹងផ្អែកលើរូបភាពSPOT 1998-2002
- ព្រំប្រទល់ស្រុក ឃុំ ទីប្រជុំជន មានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន

ជ ខ ត ល

មាត្រដ្ឋាន ១ : ៣០ ០០០

0 0.5 1 2 3 4 គីឡូម៉ែត្រ

សិក្សាដោយ: គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកណ្ដាល
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកកោះធំ
គាំទ្របច្ចេកទេសដោយ: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

លេខ: ០០៥ ..................
បានឃើញនិងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ..........ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី ២៤ ខែ..........ឆ្នាំ២០១៨
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**
ជា សុផារ៉ា

លេខ: ..................
បានឃើញ និងពិនិត្យត្រឹមត្រូវ
គោរពជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ..........ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី ២១ ខែ..........ឆ្នាំ២០១៨
**អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**
បណ្ឌិត បឺន_សុដល

លេខ: ..................
បានឃើញនិងឯកភាព
គោរពជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។
ធ្វើនៅខេត្តកណ្ដាល ថ្ងៃ..........ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី ១៣ ខែ..........ឆ្នាំ២០១៨
**អភិបាលនៃគណៈអភិបាលខេត្ត និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្ដាល**
ម៉ៅ ភិរុណ

លេខ: ..................
បានឃើញនិងឯកភាព
គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្ដាល មេត្តាពិនិត្យ និងសម្រេច។
ធ្វើនៅស្រុកកោះធំ ថ្ងៃ..........ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី ០៥ ខែ..........ឆ្នាំ២០១៨
**អភិបាលនៃគណៈអភិបាលស្រុក និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ស្រុកកោះធំ**
អេង_មោរ៉ា